ព្រះរាជាណាចក្រកម្ពុជា

ចា ស្រីពៅ

## សំណួរ_ចម្លើយ

# ប្រវត្តិវិទ្យា

## ១២







ស្របតាមកម្មវិធីសិក្សាថ្មី

# អារម្ភកថា

សៀវភៅកំណែប្រវត្តិវិទ្យាថ្នាក់ទី12 ដែលប្អូនៗកំពង់កាន់នៅនឹងដៃនេះ ត្រូវបានរៀបចំចងក្រងឡើងក្នុងគោលបំណងសម្រាប់ជាជំនួយនិងពង្រីកចំណេះដឹងរបស់ប្អូនៗសិស្សានុសិស្ស ដែលកំពង់ត្រៀមប្រលងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ។

សៀវភៅនេះមានសំណួរចម្លើយគ្រប់មេរៀនដែលមានលក្ខណៈសមស្របទៅនឹងការប្រលងនាពេលបច្ចុប្បន្ន។ខ្ញុំបានរៀបចំចងក្រងតាមលំដាប់លំដាប់លំដោយនៃមេរៀនតាមសៀវភៅសិស្សរបស់ក្រសួងអប់រំយុវជននិងកីឡាឆ្នាំ2011។

ខ្ញុំសង្ឃឹមថាសៀវភៅនេះពិតជាអាចជួយចូលរួមចំណែកផ្តល់នូវចំណេះដឹងដល់ប្អូនៗជាក់ជាមិនខានឡើយ។ទោះជាយ៉ាងណាក៏ដោយក៏សៀវភៅនេះនៅមានចំណុចខ្វះចន្លោះជាសព្វំរូច។

ខ្ញុំនឹងរងចាំទទួលនូវការរិះគន់កែលម្អពីគ្រប់មជ្ឈដ្ឋានជាពិសេសលោកគ្រូ-អ្នកគ្រូដោយសេចក្តីគោរពរាប់អានដ៏ជ្រាលជ្រៅបំផុត។

សូមប្អូនទទួលបាននូវជោគជ័យគ្រប់ការប្រលងនានា។

សូមអរគុណ!

ភ្នំពេញថ្ងៃទី7កក្កដា ឆ្នាំ2011

អ្នករៀបរៀង

**ចា ស្រីពៅ**

**ជំពូកទី១ ប្រវត្តិសាស្ត្រពិភពលោក**

**មេរៀនទី2 សហរដ្ឋអាមេរិច (1860-1960)**

## សំណួរ

1. តើផែនការញូឌៀលជាអ្វី ? នរណាជាអ្នកបង្កើតឡើង ?
2. ហេតុអ្វី បានជាសហរដ្ឋអាមេរិចក្លាយជាមហាអំណាចសេដ្ឋកិច្ច នៅក្រោយសង្គ្រាមលោកលើកទី២ ?
3. តើព្រំដែនថ្មីជាអ្វី ? ហើយមានទិសដៅអ្វីខ្លះ ?
4. ក្រោយសង្គ្រាមត្រជាក់ តើប្រទេសអឺរ៉ុបខាងកើតមានការប្រែប្រួលដូចម្តេចម្តេច ?

## ចម្លើយ

1. ផែនការញូឌៀល គឺមានន័យថាជាការជួយសង្គ្រោះសេដ្ឋកិច្ចជាបន្ទាន់តាមកំណែទម្រង់របស់រដ្ឋាភិបាល។

❖ ផែការនេះបង្កើតឡើងដោយ ប្រធានាធិបតីសហរដ្ឋអាមេរិចឈ្មោះហ្វ្រង់គ្លីន រ៉ូស្វែល ( 1933-1945 )។

2. បានជាសហរដ្ឋអាមេរិច ក្លាយជាមហាអំណាចសេដ្ឋកិច្ចនៅក្រោយសង្គ្រាមលោកលើកទី២ព្រោះ

➢ ប្រទេសនៅអឺរ៉ុបភាគច្រើនត្រូវការខ្ចីប្រាក់ពីអាមេរិចដើម្បីស្តារសេដ្ឋកិច្ចរបស់ខ្លួនឡើងវិញ

➢ សហរដ្ឋអាមេរិច បានគេចផុតពីការខ្ទេចខ្ទាំខាងសេដ្ឋកិច្ចដោយសារសង្គ្រាម

➢ អាមេរិចមានទីផ្សារច្រើននៅគ្រប់ទ្វីប

➢ ប្រជាជនប្រឹងប្រែងពង្រីកវិស័យកសិកម្ម ដើម្បីបំពេញសេចក្តីត្រូវការក្រៅប្រទេស ។

. ព្រំដែនថ្មីគឺជាការប្រយុទ្ធប្រឆាំងនឹងភាពក្រីក្រ ប្រឆាំងនឹងការប្រកាន់ពូជសាសន៍ និងការយឺតយ៉ាវផ្នែកវិទ្យា សាស្ត្របច្ចេកវិទ្យាដែលជាវិបត្តិបន្សល់ពីប្រធានាធិបតីអាណត្តិមុន។

❖ **ព្រំដែនថ្មីមានទិសដៅ៖**

➢ ធ្វើឱ្យមានកំណើនសេដ្ឋកិច្ច

➢ កាត់បន្ថយអត្រាគ្មានការងារធ្វើរបស់ប្រជាជន

➢ កាត់បន្ថយអតិផរណាប្រចាំឆ្នាំ

➢ ពង្រឹងកិត្យានុភាពអាមេរិចឡើងវិញ

➢ ធ្វើឱ្យតម្លៃប្រាក់ដុល្លារមានតុល្យភាព។

. ក្រោយសង្គ្រាមត្រជាក់ ប្រទេសអឺរ៉ុបខាងកើតមានការប្រែប្រួលដូចជា៖

➢ ផ្លាស់ប្តូររបបនយោបាយពីកុម្មុយនីសមកប្រជាធិបតេយ្យ ហើយងាកមកទទួលជំនួយពីសហរដ្ឋអាមេរិច ដើម្បីស្តារក៏ដូចជាកសាងប្រទេសជាតិរបស់ខ្លួនឡើងវិញ

➢ លែងទទួលបានជំនួយពីប្រទេសកុំម៉ុយនីស

➢ ងាកមកសហប្រតិបត្តិការសេដ្ឋកិច្ចជាមួយសហគមអឺរ៉ុប និងជាមួយប្រទេសនានាក្នុងពិភពលោក។

➢ សេដ្ឋកិច្ចទីផ្សារសេរីបានចូលមកជំនួសេដ្ឋកិច្ចផែនការ

➢ លែងរណបសហភាពសូវៀតទៀត។

# មេរៀនទី2 ចក្រភពអង់គ្លេស

## សំណួរ

1. តើប្រទេសអង់គ្លេសជាប្រទេសឈ្នះ ឬជាប្រទេសចាញ់សង្គ្រាមលោកលើកទី២ ? ព្រោះអ្វី ?
2. តើប្រទេសអង់គ្លេសមានគណបក្សសំខាន់ៗអ្វីខ្លះ?តើគណបក្សមួយណាដែលដឹកនាំប្រទេសអង់គ្លេសបានល្អជាងគេ?
3. តើលោកស្រី ម៉ាការេត ថាច់ធឺ ជាប់ឆ្នោតជានាយករដ្ឋមន្ត្រីអង់គ្លេសពីឆ្នាំណា?តើគាត់បានដោះស្រាយបញ្ហា អ្វី ?
4. វិបត្តិអ៊ុលស្ទ័រ ជាវិបត្តិធ្ងន់ធ្ងរសម្រាប់ប្រទេសអង់គ្លេស តើអង់គ្លេសដោះស្រាយដូចម្តេច?

## ចម្លើយ

1. ប្រទេសអង់គ្លេស ជាប្រទេសឈ្នះសង្គ្រាមលោកលើកទី២ ពីព្រោះប្រ្ទេសអង់គ្លេសស្ថិតនៅក្នុងសម្ព័ន្ធមិត្តអាមេរិច សហភាពសូវៀត បារាំងដែរ ដែលបានធ្វើឱ្យកងទ័ពអាឡឺម៉ង់ បរាជ័យ។

2.ប្រទេសអង់គ្លេសមានគណបក្សសំខាន់ៗចំនួនបីគឺ

- គណបក្សអភិរក្សនិយម
- គណបក្សការងារនិយម
- គណបក្សសេរីនិមយ

❖គណបក្សដែលដឹកនាំប្រទេសបានល្អជាងគេគឺគណបក្សអភិរក្សនិយម។

3. លោកស្រី ម៉ាការេត ថាច់ឆឺ ជាប់ឆ្នោតជានាយករដ្ឋមន្ត្រីអង់គ្លេសពីឆ្នាំ1979ដល់ឆ្នាំ1990 ។

❖គាត់បានដោះស្រាយបញ្ហាដូចជា

➢វិបត្តិប្រេងឡើងថ្លៃ

➢វិបត្តិសេដ្ឋកិច្ច

➢កាត់បន្ថយអតិផរណា។

➢ធ្វើឱ្យមានការគាំទ្រពីគណៈបក្សប្រឆាំង។

4. វិបត្តិអ៊ុលស្ទ័រ ជាវិបត្តិធ្ងន់ធ្ងរសម្រាប់ប្រទេសអង់គ្លេស។

❖អង់គ្លេសបានដោះស្រាយ ដោយរដ្ឋាភិបាលអង់គ្លេសបានបើកកិច្ចចរចា ជាមួយចលនាកងទ័ពសាធារណរដ្ឋអៀរឡង់ដើម្បីបញ្ចប់ជំលោះនៅទីក្រុង បែលហ្វាស នៅឆ្នាំ1998។ វិបត្តិនេះបានបញ្ចប់ដោយអង់គ្លេសបាន បង្កើតរដ្ឋាភិបាលមួយដែលមានសមាជិកពីនិកាយទាំងពីររួមគ្នាគឺកាតូលិកនិងប្រូតេស្តង់។

## មេរៀនទី3 សាធារណរដ្ឋបារាំង( Rublic of France )

### សំណួរ

1. តើប្រទេសបារាំងជាអ្នកឈ្នះ ឬជាអ្នកចាញ់សង្គ្រាមលោកលើកទី២ ?
2. តើអ្នកណារំដោះប្រទេសបារាំងចេញពីហ្វាស៊ីសអាឡឺម៉ង់ ?
3. ចូររៀបរាប់ពីរបបសាធារណរដ្ឋទី៤ និងទី៥ ។
4. ហេតុអ្វីបានជាលោកសាលដឺហ្គោល ធ្លាក់ពីដំណែងប្រធានាធិបតី ?
5. តើនយោបាយក្រៅប្រទេសរបស់បារាំងក្នុងសាធារណរដ្ឋទី៥ មានគោលដៅអ្វីខ្លះ ?

### ចម្លើយ

1. ប្រទេសបារាំងជាអ្នកឈ្នះ សង្គ្រាមលោកលើកទី២។ពីព្រោះបារាំងក៏ស្ថិតនៅក្នុងសម្ព័ន្ធមិត្តអាមេរិចដែរ។
2. អ្នកដែលរំដោះប្រទេសបារាំង ចេញពីហ្វាស៊ីសអាឡឺម៉ង់គឺលោកសាល ដឺហ្គោល ដោយមានជំនួយពីសម្ព័ន្ធមិត្តគឺអង់គ្លេស និងសហរដ្ឋអាមេរិច ។

3. រៀបរាប់ពីរបបសាធារណរដ្ឋទី៤ និងទី៥

## ❖សាធារណរដ្ឋទី4

បក្សកុំម៉ុយនីសបារាំង និងពួកកម្មករបានក្លាយជាកម្លាំងនយោបាយសំខាន់បំផុតរបស់ប្រទេសបារាំង និងមានឥទ្ធិពលក្នុងការរៀបចំគណៈរដ្ឋមន្ត្រីព្រោះទទួលបានសន្លឹកឆ្នោតជាងប្រាំលានសំលេង។ខែកញ្ញាឆ្នាំ 1946 រដ្ឋសភាបារាំងបានអនុម័តរដ្ឋធម្មនុញ្ញថ្មីហើយបង្កើតសាធារណរដ្ឋទី4 និងផ្តល់លទ្ធភាពឱ្យរដ្ឋាភិបាលក្នុងការធ្វើកំណែទម្រង់ប្រព័ន្ធសេដ្ឋកិច្ចដែលខ្ទេចខ្ទាំដោយសារសង្គ្រាមកន្លងមក។

របបសាធារណរដ្ឋទី៤មានរដ្ឋធម្មនុញ្ញបង្កើតនៅឆ្នាំ1946 ដែលប្រគល់អំណាចទៅឱ្យសភាជាអ្នកជ្រើសរើសនាយករដ្ឋមន្ត្រីដែលមានអណត្តិ5ឆ្នាំ និងត្រួតពិនិត្យជាប្រចាំនូវសកម្មភាពនយោបាយដោយសភា ហើយសភាអាចដកហូតតំណែងគ្រប់ពេលវេលាបើសិនជាមានកំហុសឆ្គង។ ដូចនេះរបបនេះប្រគល់អំណាចធំធេងដល់សភា ក្នុងការកំណត់អំណាចនីតិប្រតិបត្តិ ចំណែកប្រធានាធិបតីក៏ជ្រើសតាំងដោយសភាដែរសម្រាប់អាណត្តិ7ឆ្នាំ ប៉ុន្តែពុំមានអំណាចទូលំទូលាយដូចសហរដ្ឋអាមេរិច ដែលផ្តលអំណាចដល់ប្រធានាធិបតី ជាអ្នកចាត់

ចែងផ្តាច់មុខនៅលើកិច្ចការទាំងមូលរបស់ ប្រទេសជាតិ ។ ដឺហ្គោលបានចោទសភាសាធារណរដ្ឋទី4ថា ជាសភាបក្ស។

នៅឆ្នាំ1946សភាបានតែងតាំងប្រធានាធិបតីមកពីគណបក្សសង្គមនិយម វាំងសង់ អូរីយ៉ូល ដូចនេះសាធារណរដ្ឋទី4បានត្រូវបង្កើតឡើង ។

❖ **សាធារណរដ្ឋទី5**

រដ្ឋធម្មនុញ្ញនៃសាធារណរដ្ឋទី5 ខុសគ្នាពីរដ្ឋធម្មនុញ្ញនៃសាធារណរដ្ឋមុនៗដោយរដ្ឋធម្មនុញ្ញនេះប្រគល់អំណាច ដ៏ទូលំទូលាយដល់ប្រធានាធិបតី ។ ប្រធានាធិបតីជ្រើសតាំងដោយការបោះឆ្នោតមានអាណត្តិ7ឆ្នាំអាចឈរបាន2អាណត្តិមាន សិទ្ធិរំលាយសភារុះរើគណៈរដ្ឋមន្ត្រីជាមេបញ្ជាការកងទ័ពជាតិ ជាអ្នកជ្រើសតាំងនាយករដ្ឋមន្ត្រីនិងមន្ត្រីផ្សេងៗតាមការស្នើសុំ របស់នាយករដ្ឋមន្ត្រី ។ ក្រៅពីនេះប្រធានាធិបតីទទួលសារតាំងចុះ ហត្ថលេខាលើសន្ធិសញ្ញាក្រឹត្យនិងបទបញ្ជាផ្សេងៗ។ ចំណែកឯតួនាទីសភាគឺសភាតំណាងរាស្ត្រមានអាណត្តិ5ឆ្នាំ ជ្រើសតាំងដោយការបោះឆ្នោតជាសកលមានតួនាទីអនុម័តច្បាប់ និងផែនការថវិកាជាតិសម្រាប់ឆ្នាំសារពើពន្ធនីមួយៗត្រួតពិនិត្យការងារ របស់រដ្ឋាភិបាលមានសិទ្ធិរំលាយរដ្ឋាភិបាលដោយអនុលោមតាមសំលេង $\frac{2}{3}$ ដាច់ខាត។

ព្រឹទ្ធសភាមានអាណត្តិ៩ឆ្នាំចប់អាណត្តិមិនព្រមគ្នាទេ សមាជិកចំនួន $\frac{1}{3}$ ត្រូវប្តូររាល់3ឆ្នាំម្តង ព្រឹទ្ធសភាមានភារកិច្ចចូល រួមតាក់តែងនិងងនុម័តច្បាប់ព្រមទាំងកញ្ចប់ថវិកាជាតិ។

4. បានជាលោកសាលដឺហ្គោល ធ្លាក់ពីដំណែងប្រធានាធិបតីពីព្រោះលោកមិនអាចដោះស្រាយវិបត្តិដែលបានកើតឡើងបាន។

❖ វិបត្តិទាំងនោះមានដូចជា

- ពួកកសិករក្រីក្រលក់ផលិតផលមិនចេញ,
- ពួកពាណិជ្ជករតូចតាចក្ស័យធន,
- កម្មករបាត់បង់ការងារនឹង គ្មានការធ្វើកាន់តែច្រើន
- កម្មកររាប់សែននាក់នាំគ្នាធ្វើកូដកម្មព្រោះ បាត់បង់ការងារ និងប្រាក់ខែមិនគ្រប់គ្រាន់
- វិស័យរដ្ឋបាលត្រូវរាំងស្ទះ។

5. នយោបាយក្រៅប្រទេសរបស់បារាំងក្នុងសាធារណរដ្ឋទី៥ មានគោលដៅ៖

- រក្សាសន្តិសុខពិភពលោក
- ភ្ជាប់ទំនាក់ទំនងអន្តរជាតិទាំងវិស័យនយោបាយ និងវិស័យសេដ្ឋកិច្ច
- ពង្រីកតួនាទីមហាអំណាច

# មេរៀនទី4 **សហព័ន្ធអាឡឺម៉ង់**( 1945-1991 )

## សំណួរ

1. ហេតុអ្វីបានជាអាឡឺម៉ង់បែកបាក់ជាពីរ ? នៅថ្ងៃខែឆ្នាំណា ?
2. តើកត្តាអ្វីដែលធ្វើឲ្យប្រទេសអាឡឺម៉ង់បង្រួបបង្រួមគ្នាវិញ ? នៅថ្ងៃខែឆ្នាំណា ?
3. ចូរនិយាយពីវិស័យសេដ្ឋកិច្ចនិង សង្គមនៅអាឡឺម៉ង់ខាងលិច ?

## ចម្លើយ

1. បានជាអាឡឺម៉ង់បែកបាក់ជាពីរ ដោយសារ ៖

➢ ការប្រឈមមុខដាក់គ្នារវាងមហាអំណាចទាំងពីរសហភាព សូវៀតនិងសហរដ្ឋអាមេរិច

➢ សន្និសីទយ៉ាល់តាដែលបែងចែកប្រទេលអាឡឺម៉ងជា4 តំបន់ត្រួតត្រាដើម្បីកុំឱ្យប្រទេសនេះ មានលទ្ធភាពបង្ករសង្គ្រាមទៀត

❖ អាឡឺម៉ង់បែកជាពីរនៅថ្ងៃទីទី 12 សីហា 1948

2. កត្តាដែលធ្វើឲ្យប្រទេសអាឡឺម៉ង់បង្រួបបង្រួមគ្នាវិញព្រោះ ៖

➢ សហភាពសូវៀតពុំមានលទ្ធភាពក្នុង ការជួយដល់អាឡឺម៉ង់ខាងកើតដោយសារតែវិបត្តសេដ្ឋកិច្ចដ៏ធ្ងន់ធ្ងរ

➢ ការដួលរលំនៃសហភាពសូវៀត

➢ប្រទេសមហាអំណាចបានយល់ព្រមដោះលែងប្រទេសអាឡឺម៉ង់ឱ្យមានសេរីភាព

❖អាឡឺម៉ង់បង្រួបបង្រួមគ្នាឡើងវិញនៅថ្ងៃ12ខែកញ្ញា ឆ្នាំ 1990

3.និយាយពីវិស័យសេដ្ឋកិច្ចនិងសង្គមនៅអាឡឺម៉ង់ខាងលិច

❖**វិស័យសេដ្ឋកិច្ច**

សេដ្ឋកិច្ចអាឡឺម៉ង់ខាងលិចមានការរីកចម្រើន ដោយសារ ប្រទេសនេះមានតំបន់ធ្យូងថ្មដ៏ធំគឺតំបន់រ៉ួដែលជាប្រភពថាមពលសម្រាប់រោងចក្រធំៗ មានរោងចក្រស្លដែកជា ដើម ។ ហើយក៏សំបូរទៅដោយហត្ថករដោយមានប្រាក់កំរៃថោក។ ចាប់ពីឆ្នាំ1951 គេបានពង្រីកតំបន់ឧស្សាហកម្មធំៗជាច្រើននៅទូទាំងប្រទេស ។ឧស្សាហកម្មដ៏ល្បីនាំមុខគេនៅទ្វីបអឺរ៉ុបរបស់អាឡឺម៉ង់គឺ រោងចក្រគ្រឿងអគ្គិសនី រោងចក្រគីមី រោងចក្រស្លដែក និងរោងចក្រផលិតគ្រឿងម៉ាស៊ីនធំៗ។ អាឡឺម៉ង់គឺ ជាប្រទេសនាំមុខគេខាងផ្នែកផលិតផលកសិកម្មផងដែរដូចជា ស្ករ ទឹកដោះ សាច់ ។

❖**វិស័យសង្គម**

សហព័ន្ធអាឡឺម៉ង់ ជាប្រទេសមួយដែលបានគិតនៅក្នុង វិស័យសង្គមល្អជាងគេនៅទ្វីបអឺរ៉ុប ចាប់ពីប្រាក់ធានារ៉ាប់រងជំងឺការងារ អ្នកឥតការងារធ្វើ មនុស្សវ័យជរានិយាយរួមគឺ

ប្រជាជន 80%ទទួលបានប្រាក់ជានារ៉ាប់រង បើគិតជាទឹកប្រាក់សរុប មានចំនួន5 741 ពាន់លានម៉ាកនៅក្នុងឆ្នាំ1985 ។ ស្ត្រីមាន សិទ្ធិស្មើនឹងបុរសដែលមានចែងនៅក្នុងច្បាប់ជាមូលដ្ឋានស្ត្រី ចំនួន$\frac{1}{2}$ ចាប់ពីអាយុ15ដល់50 ឆ្នាំទទួលបានការងារនៅក្រៅផ្ទះ។ តាមច្បាប់ស្ត្រីមានផ្ទៃពោះត្រូវបានឈប់សម្រាកនៅផ្ទះ ចំនួន6 ខែក្រោយពេលឆ្លងទន្លេដើម្បីថែរក្សាទារក។

## មេរៀនទី5 ប្រទេសអ៊ីតាលី (Italy)

### សំណួរ

1. ចូបង្ហាញស្ថានភាពភូមិសាស្ត្រប្រទេសអ៊ីតាលី ។
2. តើសាធារណរដ្ឋអ៊ីតាលីកើតឡើងនៅឆ្នាំណា ?មានរបនាសម្ព័នអ្វីខ្លះ ?
3. តើសេដ្ឋកិច្ចប្រទេសអ៊ីតាលីពឹងផ្អែកលើវិស័យអ្វីខ្លះ។ ចូររៀបរាប់វិស័យទាំងនោះ ?
4. ប្រទេសអ៊ីតាលីសំបូរខាងស្លាបត្យកម្មបុរាណ តើបច្ចុប្បន្ននេះ រីកចម្រើនដែរឬទេ ?ព្រោះអ្វី ?
5. តើពាណិជ្ជកម្មអ៊ីតាលីមានអ្វីខ្លះ ?

## ចម្លើយ

1. ស្ថានភាពភូមិសាស្ត្រប្រទេសអ៊ីតាលី ៖

ប្រទេសអ៊ីតាលីស្ថិតនៅអឺរ៉ុបប៉ែកខាងត្បូង មានផ្ទៃក្រលា 301 230 $Km^2$ មានប្រជាជន58 លាននាក់ (ឆ្នាំ2006) ។ ប្រទេសអ៊ីតាលីលាតសន្ធឹងពីជើងទៅត្បូង សំបូរដោយភ្នំ ខ្ពង់រាប និងវាល ទំនាបចំនួន$\frac{3}{4}$នៃផ្ទៃប្រទេស។ អ៊ីតាលី មានកោះពីរសំខាន់គឺ កោះស៊ីស៊ីលនិងសាដែង ស្ថិតនៅក្នុងលំហសមុទ្រមេឌីទែរ៉ាន់េ។

2. សាធារណរដ្ឋអ៊ីតាលីកើតឡើងនៅឆ្នាំ1946។ មានរចនាសម្ព័ន្ធដូចជា៖

- ប្រធានាធិបតី៖ ត្រូវបោះឆ្នោតជ្រើសតាំងដោយព្រឹទ្ធសភានិងសភាតំណាងរាស្ត្រមានអាណត្តិ7ឆ្នាំ។ប្រធានាធិបតីមានតួនាទីជាអ្នកតែងតាំងនាយករដ្ឋមន្ត្រីនិងមានសិទ្ធិរំលាយសភា ហើយរៀបចំឱ្យមានការបោះឆ្នោតសារជាថ្មី។សិទ្ធិពិសេស មួយទៀតគឺ ប្រធានាធិបតីជាមេបញ្ជាការជាន់ខ្ពស់នៃកងទ័ព ព្រមទាំងមានសិទ្ធិប្រកាសសង្គ្រាមទៀតផង។
- សភា៖ សភាទាំងពីរគឺព្រឹទ្ធសភានិងសភាតំណាងរាស្ត្រមានសិទ្ធិក្នុងការអនុម័តច្បាប់។ សភានិងព្រឹទ្ធ សភាមានអាណត្តិ5ឆ្នាំ។

➢ **នាយករដ្ឋមន្ត្រី៖** ជាមន្ត្រីសំខាន់ក្នុងរដ្ឋាភិបាល ។ នាយករដ្ឋមន្ត្រីត្រូវបានតែងតាំងដោយប្រធានាធិបតី តាមរយៈការបោះឆ្នោតទុកចិត្តពីសភា។ចំណែកឯគណៈរដ្ឋមន្ត្រីត្រូវជ្រើសតាំងដោយនាយកមន្ត្រី ហើយត្រូវតែងតាំងដោយប្រធានាធិបតីតាមរយៈការសុំសេចក្តីទុកចិត្តពីសភានិងក្រោយការផ្តល់ការទុកចិត្តពីសភានាយករដ្ឋមន្ត្រីនិងគណៈរដ្ឋមន្ត្រីជារដ្ឋាភិបាលស្របច្បាប់។

3.សេដ្ឋកិច្ចប្រទេសអ៊ីតាលីពឹងផ្អែកលើវិស័យជាច្រើនដូចជា៖

➢ ធនធានរ៉ែ

➢ វិស័យពាណិជ្ជកម្ម

➢ វិស័យទេសចរណ៍

➢ វិស័យកសិកម្ម។

4. ប្រទេសអ៊ីតាលីសំបូរខាងស្ថាបត្យកម្មបុរាណ បច្ចុប្បន្ននេះមានការរីកចម្រើនដែរ ព្រោះរាល់សំណង់ដែលជាមរតកគឺពួកគេថែរក្សាបានឱ្យនៅល្អរហូតដល់សព្វថ្ងៃ។

5. ពាណិជ្ជកម្មអ៊ីតាលីមានការនាំចេញ សំលៀកបំពាក់ព្រោះជាប្រទេសល្បីខាងផ្នែម៉ូតនាំមុខគេលើពិភពលោក។ក្រៅពីនេះមានស្បែកជើង រថយន្ត(Fiat) ម៉ាស៊ីនគ្រប់ប្រភេទ ដែកថែប គីមី

និងផលិតផលកសិកម្ម។ ផលិតផលនាំចូលមាន ប្រេងកាត រ៉ែ កំណាត់សំពត់ ស្រូវសាលី និងសាច់។

**មេរៀនទី6 សហភាពសូវៀត** (1945-1991)

## សំណួរ

1. ចូររៀបរាប់ពីការកសាងរបបសង្គមនិយមរបស់លោកស្តាលីន និងគ្រូតឆូវ ?
2. ចូរពណ៌នាពីស្ថានភាពសង្គមនិងសេដ្ឋកិច្ចសហភាពសូវៀតក្រោយសង្គ្រាមលោកលើកទី2 ?
3. តើលោកប្រេស្នេវ បានជួយអភិវឌ្ឍសង្គមនិងសេដ្ឋកិច្ចសហភាពសូវៀតដូចម្តេចខ្លះ ?
4. ចូរវិភាគពីនយោបាយពេរេស្ត្រូយការ របស់លោកហ្គោបាឆូវ ?
5. ចូរធ្វើការប្រៀបធៀបវិស័យនយោបាយ របស់លោកស្តាលីន និងលោកប្រេស្នេវ ?
6. តើហេតុអ្វីសហភាពសូវៀតផ្តល់ជំនួយឱ្យអឺរ៉ុបខាងកើត ?
7. ចូរពន្យល់ពីបក្សសម្ព័ន្ធវ៉ាសូវីនិងអង្គការកូមេកុង ?
8. តើកត្តាអ្វីខ្លះធ្វើឱ្យបរាជ័យវិស័យកសិកម្មសូវៀត ?
9. តើរដ្ឋណាខ្លះប្រកាសឯករាជ្យពីសហភាពសូវៀត? ព្រោះអ្វី ?
10. មូលហេតុចម្បងអ្វីខ្លះបណ្តាលឱ្យសហភាពសូវៀតដួលរលំ ?

## ចម្លើយ

1. រៀបរាប់ពីការកសាងរបបសង្គមនិយមរបស់លោកស្តាលីន និង គ្រូតឆូវ ៖

❖ការកសាងរបបសង្គមនិយមរបស់ស្តាលីន

ក្រោយសង្គ្រាមលោកលើកទី2 គំរោងកសាងប្រទេសត្រូវផ្តើមពីជំហានដំបូងដោយពឹងផ្អែកលើការកសាងផែនការសេដ្ឋកិច្ចដោយចាប់ផ្តើមបន្តអនុវត្តផែនការ5ឆ្នាំលើកទី4និងទី5។

ការពង្រឹងអំណាចរបស់ស្តាលីនធ្វើឡើងតាមរយៈការងារសន្តិសុខដែលដឹកនាំដោយដាណូវ (Danov) ជាអ្នកតាមដានជួរបញ្ញាវន្តដែលតែងតែប្រឆាំងឬបញ្ចេញយោបល់រិះគន់ របបស្តាលីន ។

❖ការកសាងរបបសង្គមនិយមរបស់គ្រូតឆូវ ៖

នៅឆ្នាំ1956 មហាសន្និបាតបក្សកុំមុយនីសលើកទី20 ដែលកោះហៅដោយគ្រូតឆូវ បានផ្តោតទៅលើការរៀបចំវិស័យនយោបាយថ្មី គឺធ្វើឱ្យសម្រេចនៅក្នុងរយៈពេល4ឆ្នាំ។លោកគ្រូតឆូវជាអ្នកកែប្រែកំហុសនយោបាយសេដ្ឋកិច្ច និងយោធាដែលបន្សល់ទុកពីរបបស្តាលីន។ លោកគ្រូតឆូវបានបង្កើតផែនការលើកទី6 នៅឆ្នាំ1959 ដើម្បីជំរុញការអភិវឌ្ឍសេដ្ឋកិច្ចសហភាពសូវៀតឱ្យទាន់ សហរដ្ឋអាមេរិចនៅឆ្នាំ1980គឺមានរយៈពេល20ឆ្នាំ ។

2. ពណ៌នាពីស្ថានភាពសង្គមនិងសេដ្ឋកិច្ចសហភាពសូវៀត ក្រោយសង្គ្រាមលោកលើកទី2

❖ស្ថានភាពសង្គម

មានគាប់សង្កត់ទៅលើអ្នកដែលរិះគន់របបដឹកនាំ របស់ពួកកុំម៉ុយនីសដោយបង្ក្រាបយ៉ាងសាហាវព្រៃផ្សៃ ព្រមទាំងចាប់យកទៅដាក់គុក ឬដាក់ទណ្ឌកម្មឱ្យធ្វើការយ៉ាងធ្ងន់ធ្ងរបំផុត។ ក្រោយពីមរណៈភាពរបស់ស្តាលីនបាន បន្ធូរភាពរឹតត្បិតលើសេរីភាពរបស់អ្នករិះគន់ខ្លះៗ ហើយនឹងធ្វើឱ្យជីវភាពប្រជាជនកាន់តែប្រសើរ។

❖សេដ្ឋកិច្ច

សេដ្ឋកិច្ចសហភាពសូវៀត ក្រោយសង្គ្រាមលោកលើកទី2 បានទទួលរងនូវការខូចខាតយ៉ាងដំណំ។ ការកសាងសេដ្ឋកិច្ចដោយអនុវត្តផែនការ 5ឆ្នាំដែលលទ្ធផលទទួលបានជោគជ័យគួរជាទីពេញចិត្ត ដែលធ្វើឱ្យសេដ្ឋកិច្ចសូវៀតរីកចម្រើនមិននឹកស្មានដល់។មានការពង្រីកអណ្តូងរ៉ែ ឆ្ពោះទៅពង្រឹង រោងចក្រ និងផ្លូវដែកឱ្យបានច្រើនខ្សែថែមទៀត។ ជម្រុញទៅលើវិស័យបច្ចេកវិជ្ជា និងកសិកម្មយ៉ាងខ្លាំង។

. លោកប្រេស្នេវ បានជួយអភិវឌ្ឍសង្គមនិងសេដ្ឋកិច្ចសហភាពសូវៀតដូចជា៖

លោកបានខិតខំដោះស្រាយវិបត្តិ ដែលកើតមាននៅក្នុងសហភាពសូវៀតដោយអនុវត្តផែនការ5លើកទី11 ប៉ុន្តែលទ្ធផលសេដ្ឋកិច្ចទទួលបានតិចតួចមិនហួសពី3.5% ។ ដើម្បីបំពេញនូវការខាតបង់នៃជញ្ជីងពាណិជ្ជកម្មសូវៀត បានបង្កើនការនាំចេញនូវឧស្ម័នធម្មជាតិ និងប្រេងកាតដែលមានតំលៃរហូតដល់12 ពាន់លានដុល្លារអាមេរិចក្នុងមួយឆ្នាំ។ ចំណែកឯវិស័យសង្គមវិញលោកបានបន្ធូបន្ថយនូវការបង្ក្រាបខ្លះៗ ចំពោះអ្នកដែលរិះគន់មកលើអ្នកនយោបាយ។

. វិភាគពីនយោបាយពេរេស្រ្តូយការរបស់លោកហ្គោបាឆូវ ៖

ជាលើកដំបូងលោក ហ្គោបាឆូវបានបើកឱ្យមានវិនិយោគទន់ខាងវិស័យឧស្សាហកម្ម មកពីខាងក្រៅ ហើយបំផុសឱ្យមានការប្រណាំងប្រជែងតាម ទម្រង់សេដ្ឋកិច្ចរបបទីផ្សារសេរី ។

ក្នុងវិស័យនយោបាយវិញគឺបើកឱ្យពួកប្រឆាំង ធ្វើការរិះគន់ជាំហដល់របបមុន( សង្គមនិយម )។ នៅក្នុងក្របខ័ណ្ឌនៃជួរគណបក្សផ្តល់ឱ្យមានរបបប្រជាធិបតេយ្យនៅក្នុងបក្ស ពោលគឺឱ្យមានការជ្រើសរើសមន្ត្រីដោយការបោះឆ្នោតដើម្បីសំដែងការទុកចិត្ត។ និយាយរួមគឺកំណែទម្រង់នេះគឺឈានទៅរកលទ្ធិ

ប្រជាធិបតេយ្យ និងសេដ្ឋកិច្ចទីផ្សារសេរី។

4. ធ្វើការប្រៀបធៀបវិស័យនយោបាយ របស់លោកស្តាលីន និង លោកប្រេស្នេវ

❖ **វិស័យនយោបាយ របស់លោកស្តាលីន**

➢ មានការពង្រឹងវិស័យយោធា

➢ រឹតបន្តឹងសេរីភាពនៃការបញ្ចេញមតិ

➢ ការសាងផែនការ5ពីរលើកទទួលបានជោគជ័យ

❖ **វិស័យនយោបាយរបស់លោកប្រេស្នេវ**

➢ មាការបន្ធូរបន្ថយខ្លះចំពោះអ្នកដែលរិះគន់ឬសិទ្ធិបញ្ចេញមតិ យោបល់

➢ កសាងផែនការ5មួយលើកតែលទ្ធផលមិនបានល្អ។

5. បានជាសហភាពសូវៀតផ្តល់ជំនួយឱ្យអឺរ៉ុបខាងកើត ពីព្រោះ ដើម្បីពង្រីកមនោគមវិជ្ជាកុំមុយនីស។

6. ពន្យល់ពីបក្សសម្ព័ន្ធវ៉ាសូវីនិង អង្គការកូមេកុង

❖ **បក្សសម្ព័ន្ធវ៉ាសូវី**

គឺជាអង្គការបង្កើតនៅថ្ងៃ14 មិថុនា 1955 មានសមាជិកជា ប្រទេសកុំមុយនីស នៅអឺរ៉ុបខាងកើតសម្រាប់ប្រឆាំងនឹងអង្គ ការអូតង់របស់ពួកមូលធនអាមេរិច ។ ប្រទេសជាមាជិកមាន

អាល់បានី, ប៊ុលការី, រ៉ូម៉ានី, ហុងគ្រី, ប៉ូឡូញ,ឆេហ្គោស្លូវ៉ាគី, និងសហភាពសូវៀត ។

❖**អង្គការកូមេកុង៖**

គឺជាអង្គការជំនួយសេដ្ឋកិច្ចទៅវិញទៅមក បង្កើតឡើងនៅឆ្នាំ 1949 សម្រាប់ត្រួតពិនិត្យសេដ្ឋកិច្ចនៃបណ្តាប្រទេសក្រោមអាណាព្យាបាលសហភាពសូវៀត។ ផលិតផលដែលផលិតបានពីរោងចក្រប្រើប្រាស់បានតែនៅក្នុងស្រុក និងនៅតាមផ្សាររវាងប្រទេសគ្នាឯង មិនអាចនាំចេញទៅលក់នៅទីផ្សារប្រទេសសេរីបានឡើយ ។ ការរៀបចំសេដ្ឋកិច្ចរបស់ខ្លួនត្រូវធ្វើតាមផែនការកម្ម និងត្រួតពិនិត្យដោយសហភាពសូវៀតតម្រូវតាមសេចក្តីត្រូវការរបស់ខ្លួន។

7. កត្តាដែលធ្វើឱ្យបរាជ័យវិស័យកសិកម្មសូវៀត គឺ

➢ ការប្រើប្រាស់ជីនិងថ្នាំសំលាប់សត្វល្អិតហួសប្រមាណ
➢ ដីខ្សោះជីជាតិ
➢ គ្មានបច្ចេកទេសច្បាស់លាស់កក្នុងគំរូផលិតកម្ម។

9. រដ្ឋដែលប្រកាសឯករាជ្យពីសហភាពសូវៀតគឺ អាឡឺម៉ង់ខាងកើត ឆេកូស្លូវ៉ាគី ហុងគ្រី ប៊ុលការី និងប្រទេសបីនៅមាត់សមុទ្របាល់ទិច ព្រោះសហភាពសូវៀតសូវៀតដួលរលំ និងអ្នកដឹកនាំហ្គោបាឆូវ ប្រកាសថា នឹងមិនអនុញ្ញាតឲ្យមាន

ការធ្វើអន្តរាគមន៍ខាងវិស័យយោធាទៀតឡើយ ។

10. មូលហេតុចម្បង ដែលបណ្តាលឱ្យសហភាពសូវៀតដួលរលំ គឺ ៖

➢ មានបញ្ហាសេដ្ឋកិច្ចដ៏ធ្ងន់ធ្ងរ ការប្រណាំងប្រជែងសព្វាវុធ និងបច្ចេកវិទ្យាជាមួយសហរដ្ឋអាមេរិចដែលធ្វើឱ្យសហភាពសូវៀតចំណាយប្រាក់សន្ធឹក សន្ធាប់រហូតដល់មានវិបត្តិ

➢ ជាប្រទេសទី1ក្នុងពិភពលោកដែលកសាងប្រទេសសង្គមនិយម

➢ ការហ៊ុំព័ទ្ធដោយសេដ្ឋកិច្ចទីផ្សារសេរី។

## មេរៀនទី7 សាធារណរដ្ឋប្រជាធិបតេយ្យអាឡឺម៉ង់

### សំណួរ

1. ហេតុអ្វីបានជាអាឡឺម៉ង់បែកជាពី ?
2. តើសេដ្ឋកិច្ចអាឡឺម៉ង់ខាងកើតពឹងផ្អែកលើអ្វីខ្លះ ?
3. ហេតុអ្វីបានជាសង្គមអាឡឺម៉ង់ខាងកើតមានការរីកចម្រើន ?
4. តើកត្តាអ្វីខ្លះធ្វើឱ្យអាឡឺម៉ង់រួបរួមគ្នាវិញ ?

### ចម្លើយ

**1.** បានជាអាឡឺម៉ង់បែកជាពីរដោយសារ ៖

➢ សន្ធិសីទយ៉ាលតាដែលបែងចែកប្រទេលអាឡឺម៉ងជា4 តំបន់ត្រួតត្រាដើម្បីកុំឱ្យប្រទេសនេះមានលទ្ធភាពបង្កសង្គ្រាមទៀត

➢ ការប្រឈមមុខដាក់គ្នារវាងមហាអំណាចទាំងពីរ ។

2. សេដ្ឋកិច្ចអាឡឺម៉ង់ខាងកើតពឹងផ្អែកលើ

➢ វិស័យឧស្សាហកម្ម

➢ វិស័យកសិកម្ម

➢ វិស័យពាណិជ្ជកម្ម។

3. បានជាសង្គមអាឡឺម៉ង់ខាងកើតមានការរីកចម្រើន ដោយសាររដ្ឋាភិបាលបានបើកសិទ្ធិឱ្យបុរស និងស្ត្រីមានសិទ្ធស្មើគ្នាហើយវិស័យសុខាភិបាលគឺរដ្ឋាភិបាលផ្តល់ការព្យាបាលដោយឥតបង់

ថ្លៃ លើសពីនេះវិស័យអប់រំគឺមានលក្ខណៈល្អប្រសើ ព្រោះសិស្សចាប់ពីថ្នាក់ទី 10 ឡើងទៅត្រូវរៀនបន្ថែម2ឆ្នាំសម្រាប់ថ្នាក់វិកហ្វឹននៅ មធ្យមសិក្សា3ឆ្នាំសម្រាប់សាលាមុខជំនាញ។

4.កត្តាដែលធ្វើឱ្យអាឡឺម៉ង់រួបរួមគ្នាវិញ ដោយសារៈ

- សហភាពសូវៀតពុំមានលទ្ធភាពក្នុងការជួយដល់អាឡឺម៉ង់ខាងកើតដោយសារតែវិបត្តសេដ្ឋកិច្ចដ៏ធ្ងន់ធ្ងរ
- ប្រជាជនអាឡឺម៉ង់ចង់បានសន្តិភាព សេរីភាព និងឯករាជ្យ
- ប្រទេសមហាអំណាចបានយល់ព្រមដោះលែងប្រទេសអា ឡឺម៉ង់ឱ្យមានសេរីភាព

## មេរៀនទី៤ ប្រទេសឆេកូស្លូវ៉ាគី

### សំណួរ

1. ក្រោយសង្គ្រាមលោកលើកទី2 តើប្រទេសឆេកូស្លូវ៉ាគីប្រកាន់នយោបាយបែបណា ?
2. ហេតុអ្វីបានជាក្រោយឆ្នាំ1991ប្រទេសឆេកូស្លូវ៉ាគីបែកជាពីរ ?
3. តើសេដ្ឋកិច្ចប្រទេសឆេកូស្លូវ៉ាគីមានការរីកចម្រើន ឬទេ ? ព្រោះអ្វី ?

### ចម្លើយ

1. ក្រោយសង្គ្រាមលោកលើកទី2 ប្រទេសឆេកូស្លូវ៉ាគីប្រកាន់នយោបាយបែបកុំម៉ុយនីស។
2. បានជាក្រោយឆ្នាំ 1991 ប្រទេសឆេកូស្លូវ៉ាគីបែកជាពីរ ព្រោះក្រោយពីរបបកុំម៉ុយនីសដួលរលំ មានការខ្វែងគំនិតគ្នារវាងអ្នកដឹកនាំឆែកនិងស្លូវ៉ាគីអំពីបញ្ហានយោបាយ និងសេដ្ឋកិច្ចដែលជាឧបសគ្គក្នុងការបង្កើតរដ្ឋធម្មនុញ្ញ និងនាំឱ្យមានភាពយឺតយ៉ាវក្នុងកំណែទម្រង់សេដ្ឋកិច្ច ។ នៅពាក់កណ្តាលឆ្នាំ 1993 មេដឹកនាំនៃរដ្ឋ ទាំងពីរបានពិភាក្សាអំពីការបង្កើតប្រទេសដាច់ដោយឡែកពីគ្នាគឺ សាធារណរដ្ឋឆែកនិងសាធារណរដ្ឋស្លូវ៉ាគី។
3. សេដ្ឋកិច្ចប្រទេសឆេកូស្លូវ៉ាគីមានការរីកចម្រើនដែរ ព្រោះ វិស័យឧស្សាហកម្មបានស្រូបយកកម្មករ40% នៃចំនួនប្រជាជនសកម្ម

ហើយផលិតឧស្សាហកម្មមានដូចជា កំណាត់ កញ្ចក់ ម៉ាស៊ីន ចំណីអាហារ រថយន្តក្រុង រថយន្តទេសចរណ៍ រថយន្តដឹកទំនិញ ធុនធំដែលផលិតចេញពីរោងចក្រស្វូដា។ ម៉្យាងទៀតប្រទេស នេះក៏សំបូរទៅ ដោយរ៉ែស្ទើរគ្រប់ប្រភេទដូចជា បុកស៊ីត ត្បូង ថ្ម ប្រេងកាត មាស ម៉ង់កាណែស និងអ៊ុយរ៉ាញ៉ូម ផលិតផលនាំ ចេញទៅក្រៅប្រទេសមានដូចជា ត្បូងថ្ម សម្លៀកបំពាក់ ដែក ថែប ម៉ាស៊ីន រថយន្ត ។ វិស័យកសិកម្មវិញមានដំណាំធំ ឡូង បារាំង ពោត បន្លែ និងផ្លែឈើ ក្រៅពីនេះក៏មានកសិដ្ឋានធំៗ ដូចជា មាន់ ជ្រូក ចៀម និងគោ ។

## មេរៀនទី១ ប្រទេសប៉ូឡូញ (Poland)

### សំណួរ

1. ហេតុអ្វីបានជាគេថា ប្រទេសប៉ូឡូញជាប្រកពនៃសង្គ្រាមលោកលើកទី2 ?
2. តើប្រទេសប៉ូឡូញបានខូចខាតអ្វីខ្លះ ដោយសារសង្គ្រាមលោកលើកទី2 ?
3. នៅក្រោយសង្គ្រាមលោកលើកទី2 តើប្រទេសប៉ូឡូញបានស្តារប្រទេសជាតិដោយផ្តោតលើវិស័យអ្វីខ្លះ? ចូពន្យល់ពីវិស័យនីមួយៗ ។
4. ហេតុអ្វីបានជាសហភាពសូវៀត មិនជួយសង្គ្រោះប្រទេស ប៉ូឡូញឱ្យទាន់ពេលវេលាពីក្រញាំដៃអាល្លឺម៉ង់ ?
5. តើវិស័យនយោបាយរបស់ប្រទេសប៉ូឡូញបានស្តារមុខមាត់ដូចម្តេចខ្លះ ក្រោយការដួលរលំសហភាពសូវៀត ?

### ចម្លើយ

1. បានជាគេថា ប្រទេសប៉ូឡូញជាប្រកពនៃសង្គ្រាមលោកលើកទី2ព្រោះប្រទេសប៉ូឡូញជាកន្លែងមហិចតា រវាងមហាអំណាចជិត ខាងគឺអាល្លឺម៉ង់និងសហភាពសូវៀតដែលចង់បែងចែកទឹកដីរបស់ប្រទេសប៉ូឡូញដោយចុះសន្ធិសញ្ញាជាសម្ងាត់។

2.ប្រទេសប៉ូឡូញបានខូចខាតដោយសារសង្គ្រាមលោកលើកទី2 មានដូចជា៖

- ប្រជាជនស្លាប់ប្រហែល6លាននាក់ ស្លាប់ក្នុងសង្គ្រាមលោកលើកទី2
- ប្រជាជនចំនួន2.5លាននាក់ត្រូវជំរុញឱ្យធ្វើការជាទម្ងន់នៅក្នុងប្រទេសអាឡឺម៉ង់។
- ប្រជាជនយ៉ាងហោចណាស់ មាន1លាននាក់ត្រូវគេសំលាប់នៅក្នុងជំរំប្រមូលផ្តុំអូសិច នៅទីក្រុងប្លាំងកានិងម៉ាសដា ណែក។
- ខូចខាតទ្រព្យសម្បត្តិរហូតដល់50 ពាន់លានដុល្លារ។

3.នៅក្រោយសង្គ្រាមលោកលើកទី2 ប្រទេសប៉ូឡូញបានស្តារប្រទេសជាតិដោយផ្តោតលើវិស័យឧស្សាហកម្ម និងកសិកម្ម

❖**វិស័យឧស្សាហកម្ម**

នៅក្រោយសង្គ្រាមលោកលើកទី2ប៉ូឡូញបានក្លាយជាប្រទេសឧស្សាហកម្មដោយពឹងផ្អែកលើរ៉ែក្រោមដីជាច្រើនប្រភេទ។នៅក្នុងការពង្រីកឧឿនឧស្សាកម្មប៉ូឡូញត្រូវការប្រាក់កម្ចីនិងបច្ចេកវិទ្យាពីលោកខាងលិច។ចាប់ពីឆ្នាំ1980 រដ្ឋាភិបាលបានប្រឹងប្រែងស្តារវិស័យឧស្សាហកម្ម ។ ការស្តារនេះតម្រូវឱ្យរុះរើរោងចក្រ កាត់បន្ថយកម្មករ បណ្តុះបណ្តាលបច្ចេកទេសទំនើប និងរកប្រាក់កម្ចីពីប្រទេសមួយចំនួនដូចជា

សហរដ្ឋអាមេរិច អាឡឺម៉ង់ ស៊ុយអែត អ៊ីតាលី និងបារាំងជា ដើម។

❖វិស័យនយោបាយ

នៅក្រោយសន្ធិសីទយ៉ាល់តា សូវៀតបានបង្កើតរដ្ឋា ភិបាលបណ្តោះអាសន្នឯកភាពជាតិប៉ូឡូញមួយ នៅខែ មិថុនា ឆ្នាំ1945 ក្រោយមកទៀត ដោយមានការព្រមព្រៀង ពីមហាអំណាចគេឃើញមានការចាត់ចែងឱ្យធ្វើការបោះឆ្នោតដោយសេរីមួយនៅខែមករា ឆ្នាំ1957 ដែលនៅពេលនោះពួកកុំម៉ុយនីសជាអ្នកក្តាប់អំណាចក្នុងរដ្ឋាភិបាល ។

ការដឹកនាំមិនបានល្អ ដូចជាចាប់ខ្លួនមន្ត្រីសង្ឃដាក់គុក វិបត្តិសេដ្ឋកិច្ច សាសនាការបង្ក្រាប់លើបាតុការជាដើម ។ រហូតដល់ឆ្នាំ 1990 លោកវ៉ាលេសា បានជាប់ឆ្នោតជាប្រធានាធិបតីទើបអាចដោះស្រាយវិបត្តិបាន។នៅឆ្នាំ1997 រដ្ឋធម្មនុញ្ញបានបញ្ញត្តិប្រទេសនេះទៅជាសាធារណរដ្ឋប្រជាធិបតេយ្យ ដែលប្រធានាធិបតីមានអាណត្តិ5ឆ្នាំ អមដោយនាយករដ្ឋមន្ត្រី។

❖វិស័យកសិកម្ម

ប្រទេសប៉ូឡូញនៅភាគខាងត្បូងសំបូរដីមានជីជាតិល្អ គេដាំ ស្រូវសាលី ផៃថាវស្គា និងបន្លែ។បើគិតតាមជញ្ជីញពាណិជ្ជ

កម្ម ប៉ូឡូញមានការនាំចូលច្រើនជាងការនាំចេញ។ដូចនេះត្រូវឱ្យរដ្ឋាភិបាលធ្វើយ៉ាងណាក្នុងការធ្វើឱ្យវិស័យនេះមានការរីកចម្រើន។

❖វិស័យសង្គម

រដ្ឋាភិបាលបានគិតគូរដល់មនុស្សចាស់ជរា មនុស្សពិការ និងពិសេសមនុស្សបាត់បង់សមត្ថភាពពលកម្ម ដោយផ្តល់ប្រាក់ចូលនិវត្តន៍យ៉ាងទៀងទាត់។ ចំណែកឯមន្ត្រីរាជការនៃក្រសួង មន្ទីរនានា ត្រូវរដ្ឋគិតគូរពីការចូលនិវត្តន៍អាយុ60ឆ្នាំសម្រាប់បុរស និងស្ត្រីសម្រាប់អាយុ 55ឆ្នាំ។

សម្រាប់វិស័យសុខាភិបាល វិស័យអប់រំត្រូវបានកែលម្អ ជាបន្តបន្ទាប់ចាប់ពីកក្រោយសង្គ្រាមលោកលើកទី2មក។

4. បានជាសហភាពសូវៀត មិនជួយសង្គ្រោះប្រទេសប៉ូឡូញឱ្យទាន់ពេលវេលាពីក្រញាំដៃអាឡឺម៉ង់ ព្រោះដោយសារៈ

➢នៅថ្ងៃទី4ខែមិថុនា ឆ្នាំ1941អាឡឺម៉ងបានលើកទ័ពមកវាយចូលសហភាពសូវៀត

➢នៅខែមេសាឆ្នាំ1943ចំណងមិត្តភាពរវាងប៉ូឡូញនិងសូវៀតត្រូវបានប្រេះឆាដោយសារទាហានអាឡឺម៉ង់បានរកឃើញរណ្តៅកប់ខ្មោចនាយទាហានប៉ូឡូញចំនួន 4 500នាក់ ដែលត្រូវបានតម្រួតសូវៀតសំលាប់។

5.វិស័យនយោបាយរបស់ប្រទេសប៉ូឡូញបាន ស្ដារមុខមាត់របស់ខ្លួននៅក្រោយការដួលរលំសហភាពសូវៀត គឺនៅឆ្នាំ 1997 រដ្ឋធម្មនុញ្ញបានបញ្ញត្តិប្រទេសនេះទៅជាសាធារណរដ្ឋប្រជាធិបតេយ្យ ដែលប្រធានាធិបតីមានអាណត្តិ5ឆ្នាំអមដោយនាយករដ្ឋមន្ត្រី។ ប្រធានាធិបតីជាអ្នកជ្រើសរើសមន្ត្រីតាមការស្នើសុំរបស់នាយក រដ្ឋមន្ត្រីរួចសុំសេចក្ដីអនុម័តពីសភាដោយមតិភាគច្រើន។

# មេរៀនទី10 សហព័ន្ធយូហ្គោស្លាវី

## សំណួរ

1. ចូរបង្ហាញពីមូលហេតុដែលនាំឱ្យកើតរដ្ឋស្លាវខាងត្បូង ?
2. តើក្នុងសហព័ន្ធយូហ្គោស្លាវីមានរដ្ឋជាសមាជិកប៉ុន្មាន ? អ្វីខ្លះ ?
3. តើមូលហេតុអ្វីបានជារដ្ឋទាំងនោះរួបរួមគ្នា ? ហេតុអ្វីបានជាបែកបាក់ទៅវិញ ?
4. តើសេដ្ឋកិច្ចយូហ្គោស្លាវីមានគម្រោងអ្វីខ្លះ ?
5. ហេតុអ្វីបានជាប្រទេសយូហ្គោស្លាវី ជួបប្រទះវិបត្តិសេដ្ឋកិច្ចយ៉ាងធ្ងន់ធ្ងរ ?

## ចម្លើយ

1. មូលហេតុដែលនាំឱ្យកើតរដ្ឋស្លាវខាងត្បូង គឺដោយសសារចក្រភពអូទ្រីស-ហុងគ្រី បានប្រកាសសង្គ្រាមជាមួយប្រទេសសែប៊ី នៅថ្ងៃទី28 ខែកក្កដាឆ្នាំ1914។តែសែប៊ីគាំទ្រដោយប្រទេសរូស្ស៊ី។ នៅក្រោយសង្គ្រាមលោកលើកទី១សន្និសីទអន្តរជាតិស្តីពីការបំបែកចេញពីចក្រភពអូទ្រីស ដើម្បីបង្កើតប្រទេសពីរគឺឆេកូស្លូវ៉ាគី និងយូហ្គោស្លាវីឬហៅថាស្លាវខាងត្បូង។

2. ក្នុងសហព័ន្ធយូហ្គោស្លាវីមានរដ្ឋជាសមាជិកចំនួន 6 គឺរដ្ឋសង្គមនិយមបូស្នីអ៊ែរសេកូវីន ក្រូអាត ម៉ាសេឌន ស្លូវេន ម៉ុងតេនេក្រូ និង រដ្ឋស៊ែប៊ីដែលរួមបញ្ចូលទាំងខេត្តស្វយ័ត2គឺវ៉ូសវ៉ូឌីន និងកូសូវ៉ូ ដែលមានសិទ្ធិស្មើគ្នានឹងរដ្ឋផ្សេងៗទៀតនៅក្នុងសហព័ន្ធដែរ។

3. បានជារដ្ឋទាំងនោះរួបរួមគ្នា ពីព្រោះដោយសារមានការគាំទ្រពីសហភាពសូវៀតដើម្បីប្រឆាំងជាមួយអាឡឺម៉ង់។

❖ បានជាបាក់បែកទៅវិញ ព្រោះ

- ➢ រដ្ឋនីមួយៗមានជនជាតិផ្សេងៗគ្នាពួកគេចង់បានឯក រាជរៀងខ្លួន
- ➢ មានសាសនាច្រើនចម្រុះគ្នា។

4. សេដ្ឋកិច្ចយូហ្គោស្លាវីមានគម្រោង នឹងធ្វើឱ្យយូហ្គោស្លាវីក្លាយទៅជាប្រទេសមួយរីកចម្រើន ខាសេដ្ឋកិច្ចនៅលើឧបទ្វីបបាល់កង់ដូចប្រទេសនានានៅអឺរ៉ុបខាងលិចដែរ។

5. បានជាប្រទេសយូហ្គោស្លាវី ជួបប្រទះវិបត្តិសេដ្ឋកិច្ចយ៉ាងធ្ងន់ធ្ងរ ពីព្រោះដោយសារ យូហ្គោស្លាវីចាំបាច់ខ្ចីប្រាក់ចំនួន ច្រើនលើសលប់ ដើម្បីកសាងសេដ្ឋកិច្ចលើគ្រប់វិស័យដោយពឹងផ្អែកលើការនាំចេញ។ នៅទសវត្សរ៍70 អឺរ៉ុបខាងលិចបានជួបវិបត្តិសេដ្ឋកិច្ចយ៉ាងធ្ងន់ធ្ងរ ជាពិសេសវិបត្តិថាមពលបានចោត

ជាបញ្ហាដល់ផលិតផលនាំចេញ និងធ្វើឱ្យរាំងស្ទះដង្ហើមសេដ្ឋកិច្ចយូហ្គោស្លាវី។

---

## មេរៀនទី11 បញ្ហាទូទៅក្នុងពិភពលោក

### សំណួរ

1. តើបញ្ហាអ្វីទៅដែលគេចាត់ទុកជាបញ្ហារួមលើសកលលោក ? ចូររាប់បញ្ហារួមលើសកលលោកឱ្យបានយ៉ាងតិចប្រាំ ?
2. តើស្ថានភាពបរិស្ថានធម្មជាតិលើសកលលោកទទួលការគំរាមកំហែងអ្វីខ្លះ ?
3. តើអ្វីជាប្រភពមូលដ្ឋានដែលនាំឱ្យលេចឡើងនូវបញ្ហារួមលើសកលលោក ?

### ចម្លើយ

1. បញ្ហាដែលគេចាត់ទុកជាបញ្ហារួមលើសកលលោក គឺជាបញ្ហាដែលគំរមកំហែងដល់ការរស់នៅ របស់ប្រជាជនលើសកលលោក ទាំងមូល។បញ្ហាទាំងនោះមានដូចជា បញ្ហាបរិស្ថាន បញ្ហាកំណើន ប្រជាជន បញ្ហាសន្តិសុខស្បៀង បញ្ហាភេរវកម្មអន្តរជាតិ និងបញ្ហា ជនអន្តោប្រវេសន៍ ។
2. ស្ថានភាពបរិស្ថានធម្មជាតិលើសកលលោកទទួលការគំរាមកំហែងដូចជា ៖

ការបំពុលអាកាស ដែលកើតឡើងដោយសារកាកសំណល់ពីរោងចក្រ និងផ្សែងយានយន្ត

ការបាត់បង់ស្រទាប់អូសូននៅក្នុងបរិយាកាស ដែលបណ្តាលមកពីសារធាតុពុលពីកាកសំណល់រោងចក្រ

ការឡើងកម្តៅផែនដី ដែលបង្ករគ្រោះថ្នាក់ដល់ការរស់នៅលើផែនដី

សកម្មភាពមនុស្សដូចជាកាដុតព្រៃ សារធាតុក្លរ៉ូភ្លុយអរ៉ូកាបូន (CFCS) កើតពីហ្គាសទូទឹកកកម៉ាស៊ីនត្រជាក់រថយន្តជាដើម ការធ្វើឱ្យទឹកកកង្វក់

ការចោលសំរាមជាកាកសំណល់ពីរោងចក្រ ដែលនាំឱ្យខូច បរិស្ថាននៅក្នុងទឹកនិងលើគោក

ការធ្វើឱ្យរិចរឹលនៃស្រទាប់ដី

ការបំផ្លាញព្រៃឈើធ្វើឱ្យបាត់បង់ជីវចម្រុះលើដី។

.អ្វីដែលជាប្រភពមូលដ្ឋានដែលនាំឱ្យលេចឡើងនូវបញ្ហារួមលើសកលលោកនោះគឺ៖

ប្រភពទី១ កំណើននិងទំហំសេដ្ឋកិច្ចសកលលោកមិនស៊ីចង្វាក់ទៅនឹងលទ្ធភាពពិតប្រាកដដែលផ្តល់ពីធនធាននៅលើដី

➢ប្រភពទី២ កើតចេញពីការរីកចម្រើននៃបដិវត្តន៍វិទ្យាសា[
បច្ចេកទេស
➢ប្រភពទី៣ កំណើនប្រជាជននាំឱ្យមានការផ្គត់ផ្គង់គ្រឿង[
កោគបរិភោគកាន់តែច្រើន ដោយប្រើប្រាស់ធម្មជាតិដែល [
តែរិចរិលទៅៗ ។ ការគំរាមកំហែងពីគ្រោះដោយគក គ្រ[
ទុរ្ភិក្ស មនុស្សមិនចេះអក្ស ការពុំមានទឹកស្អាតប្រើប្រាស់[
គ្មានអគ្គិសនីប្រើប្រាស់ជាដើម
➢ប្រភពទី៤ ការចំណាយធនធានយ៉ាងច្រើនសន្ទឹកសន្ធាប់[
សព្វាវុធនិងកងទ័ព
➢ប្រភពទី៥ ភាពយឺតយ៉ាវរបស់ស្ថាប័នអំណាចជាតិក្នុង[
ឆ្លើយតបនិងរកវិធីដោះស្រាយបញ្ហាឱ្យទាន់ពេលវេលា។

## មេរៀនទី12 ដំណើរការវិវត្តន៍សកលភាវូបនីយកម្ម

### សំណួរ

1. តើកត្តាអ្វីខ្លះដែលជាប្រកពជំរុញឱ្យមានការកសាងប្រព័ន្ធដឹកនាំពិភពលោកតែមួយ(សកលភាវូបនីយកម្ម) ?
2. តើរដ្ឋមានតួនាទីយ៉ាងណាក្នុងនយោបាយអន្តរជាតិ? តើចរន្តសកលភាវូបនីយកម្មអាចមានផលប៉ះពាល់យ៉ាងណា ដល់តួនាទីរដ្ឋ ?
3. ហេតុដូចម្ដេចបានជាកម្លាំងទ័ពអន្តរជាតិ តែងតែជួបនឹងបញ្ហាស្មុគស្មាញនៅក្នុងការធ្វើសកម្មភាពមនុស្សធម៌ ឬរារាំងសង្គ្រាមស៊ីវិលនៅក្នុងប្រទេសណាមួយលើសកលលោក ?

# ចម្លើយ

1. កត្តាដែលលជាប្រភព ជំរុញឱ្យមានការកសាងប្រព័ន្ធដឹកនាំពិភពលោកតែមួយ(សកលភាវូបនីយកម្ម) មានដូចជា៖

- កម្លាំងចលករនៃប្រព័ន្ធសេដ្ឋកិច្ចសកលលោកដែលជំរុញឱ្យកាន់តែលេចឡើងនូវអស្ថិរភាពននិងផលវិបាកចំពោះបញ្ហា ផ្ទៃក្នុងប្រទេស និងទំនាក់ទំនងរវាងប្រទេសលើសកលលោក
- កំណើនយ៉ាងខ្លាំងនូវបំលាស់ប្តូទីកន្លែងរស់នៅរបស់ប្រជាពលរដ្ឋនៅលើសកលលោក
- ការរីកចម្រើនយ៉ាងខ្លាំងនូវប្រព័ន្ធទំនាកទំនងទូរគមនាគមន៍អន្តរជាតិ
- ការរីកសាយភាយយ៉ាងខ្លាំងនូវបច្ចេកវិទ្យាយោធាទំនើបដែលជានិច្ចកាលបានក្លាយជាឧបករណ៍នយោបាយសកលលោក
- បញ្ហារួមជាច្រើនបានកើតឡើង ដែលទាមទារឱ្យមានកាសម្រេចបិត្តដោះស្រាយបញ្ហាទាំងនេះ តាមរយៈថ្នាក់ដឹកនាំដ្ឋាភិបាល អង្គការអន្តរជាតិ និងសហគមអន្តរជាតិជាដើម។

2. តួនាទីរដ្ឋក្នុងនយោបាយអន្តរជាតិ គឺ៖

- រដ្ឋជាឧបករណ៍ផ្តាច់មុខក្នុងការការពារបូរណភាពដែនដីខ្លួន
- រដ្ឋជាផ្នែកមួយនៃសហគមន៍អន្តរជាតិ ប៉ុន្តែរដ្ឋនីមួយៗមានដែនសកម្មភាពរបស់ខ្លួនច្បាស់លាស់ ក្នុងការធ្វើកិច្ចស

ប្រតិបត្តិការ និងកក្នុងការប្រគួតប្រជែងដើម្បីផលប្រយោជន៍ជាតិរៀងៗខ្លួន

➢ រដ្ឋមានតួនាទីយ៉ាងសំខាន់ក្នុងការផ្លាស់ប្តូរ បញ្ជូនកម្លាំងពលករទៅបំពេញការងារនៅក្រៅប្រទេសនិងការពារពួកគេគ្រប់ពេលវេលាស្របទៅតាមច្បាប់

➢ រកមធ្យោបាយគ្រប់បែបយ៉ាង ដើម្បីរក្សាតុល្យភាពរវាងកំណើនសេដ្ឋកិច្ចសេរីអន្តរជាតិជាមួយសេដ្ឋកិច្ចជាតិ

➢ គ្រប់គ្រងធនាគាក្នុងនោះមានការទទួលខុសត្រូវក្នុងការសម្របសម្រួលនិងពិនិត្យពីស្ថាប័នហិរញ្ញវត្ថុជាតិ ដែលបំពេញការងារសម្រាប់រដ្ឋាភិបាលជាដើម។

❖ **ចរន្តសកលភាវូបនីយកម្មអាចមានផលប៉ះពាល់ដល់តួនាទី រដ្ឋដូចជា៖**

➢ ធ្វើឱ្យតួនាទីនៅក្រៅរង្វង់អធិបតេយ្យរបស់ខ្លួន

➢ ធ្វើឱ្យតួនាទីរដ្ឋធ្លាក់ចុះពីព្រោះសហគ្រាសពហុជាតិ ឬសហគ្រាសអន្តរជាតិធ្វើសកម្មភាពភាគច្រើន អាស្រ័យលើដំណើរការវិវត្តនៃទីផ្សារសកលលោក ហើយគេធ្វើយ៉ាងណាឱ្យមានឯករាជភាពពីនយោបាយរដ្ឋ

➢ ធ្វើឱ្យមានភាពស្មុគស្មាញថែមទៀតដល់អធិបតេយ្យភាព របស់រដ្ឋនៅក្នុងវិស័យនយោបាយ

➢ ប្រទេសអន់ខ្សោយស្ថិតនៅក្រោមឥទ្ធិពលរបស់ប្រទេសមហាអំណាចដែលធ្វើឱ្យគ្មានទីរង្វើរមតូច

➢ ប្រទេសក្រីក្រមិនអាចដើរតាមលទ្ធិប្រជាធិបតេយ្យបាន ព្រោះប្រជាជនភាគច្រើនជាអនក្ខរជននិងសេដ្ឋកិច្ចទន់ខ្សោយ ។

3. បានជាកម្លាំងទ័ពអន្តរជាតិសតែងតែជួបនឹង បញ្ហាស្មុគស្មាញនៅក្នុងការធ្វើសកម្មភាពមនុស្សធម៌ ឬរាំងសង្គ្រាមស៊ីវិលនៅក្នុងប្រទេសណាមួយលើសកលលោក ៖

➢ ទាក់ទងនឹងការប្រើប្រាស់កម្លាំងទ័ព ច្បាប់និងសិទ្ធិប្រើប្រាស់កម្លាំងទ័ព ដើម្បីដោះស្រាយទំនាស់នៅក្នុងប្រទេស ឬតំបន់ណាមួយ

➢ ការប្រកាន់វប្បធម៌ជ្រុលនិយម សាសនានិយម និងការ ប្រកាន់វប្បធម៌ជ្រុលនិយមរបស់អ្នកដឹកនាំរដ្ឋ

➢ ការគាបសង្កត់របស់អ្នកដឹកនាំលើប្រជាជន ដោយមិនបានផ្ដល់ពត៌មានដល់សហគមន៍អន្តរជាតិ។

# សំណួរបញ្ចប់ជំពូកទី១

I. ចូរគូសសញ្ញា ✓ក្នុងប្រអប់ចម្លើយត្រឹមត្រូវ

1. តើប្រធានាធិបតីសហរដ្ឋអាមេរិចរូបណាដែលបង្កើតកម្មវិធី New Deal ?

☐ក. រូស្វែល ☐ខ. និចសុន

☐គ. ចនសុន ☐ឃ. រីគេន ។

2. តើនាយករដ្ឋមន្ត្រីចក្រភពអង់គ្លេស រូបណាដែលបានសង្គ្រោះប្រទេសអង់គ្លេសក្នុងសង្គ្រាមលោកលើកទី2 ?

☐ក. សំប៊ែឡាំង ☐ខ. ឆឺឈីល

☐គ. អេដែន ☐ឃ. ថាត់ឆឺ

3. តើមេដឹកនាំសហភាពសូវៀត រូបណាដែលសង្គ្រោះប្រទេសឱ្យរួចពីសង្គ្រាមលោកលើកទី2?

☐ក. លេនីន ☐ខ. ស្តាលីន

☐គ. គ្រូតឆូវ ☐ឃ. ហ្គោបាឆេវ

II. ចូបំពេញល្បះខាងក្រោមឱ្យបានត្រឹមត្រូវ

1. នៅក្នុងឆ្នាំ1944 លោកឧត្តមសេនីយ៍បារាំង.......................... បង្កើតរដ្ឋាភិបាលបណ្តោះអាសន្ន ។

2. ក្រោយសង្គ្រាមលោកលើកទី 2 ប្រទេសអាឡឺម៉ង់បែកជាពីរ គឺ..............................និង...................................។

3.នៅឆ្នាំ1946 រដ្ឋធម្មនុញ្ញថ្មីរបស់សហព័ន្ធយូហ្គោស្លាវីបានផ្ដល់ស្វ័យភាពដល់រដ្ឋទាំង 6 តែជាគុពិតអំណាចក្នុងកណ្ដាប់ដៃ........................................................។

III. ចូគូសភ្ជាប់ឈ្មោះប្រធានាធិបតីទៅឈ្មោះប្រទេស ។

| ឈ្មោះប្រធានាធិបតី | ឈ្មោះប្រទេស | ចម្លើយ |
|---|---|---|
| 1.កេណ្ណឺឌី | ក.សហភាពសូវៀត | 1. → |
| 2.ឌូភ្លាសហូម | ខ.សហរដ្ឋអាមេរិច | 2. → |
| 3.មីទែរ៉ង់ | គ.បារាំង | 3. → |
| 4.ទីតូ | ឃ.អង់គ្លេស | 4. → |
| 5.ប្រេស្នេវ | ង.យូហ្គោស្លាវី | 5. → |

IV. **សំណួរត្រិះរិះ**

1.តើកត្តាអ្វីខ្លះដែលជំរុញឱ្យមានការកសាងប្រព័ន្ធដឹកនាំពិភពលោកតែមួយ( សកលភាវូបនីយកម្ម) ?

2.តើបញ្ហាបរិស្ថានធម្មជាតិ បានគំរាមកំហែងពិភពលោកដូចម្ដេចខ្លះ ?

3.ហេតុអ្វីបានជាក្រោយឆ្នាំ 1991 ប្រទេសឆេកូស្លូវ៉ាគីបែកជាពីរ ?

4. ហេតុអ្វីបានជាគេថាប្រទេសប៉ូឡូញ ជាប្រភពនៃសង្គ្រាមលោកលើកទី2 ?

## ចម្លើយបញ្ចប់ជំពូកទី១

I. គូសសញ្ញា ✓ក្នុងប្រអប់ចម្លើយត្រឹមត្រូវ

1. ប្រធានាធិបតីសហរដ្ឋអាមេរិចដែលបង្កើតកម្មវិធីNew Deal គឺ

☑ក. រ៉ូស្វែល

2. នាយករដ្ឋមន្ត្រីចក្រភពអង់គ្លេសដែលបានសង្គ្រោះប្រទេសអង់គ្លេសក្នុងសង្គ្រាមលោកលើកទី2 គឺ៖

☑ខ. ឆឺឈីល

3. មេដឹកនាំសហភាពសូវៀតដែលសង្គ្រោះប្រទេសឱ្យរួចពីសង្គ្រាមលោកលើកទី2គឺ

☑ខ. ស្តាលីន

II. បំពេញឈ្មោះខាងក្រោមឱ្យបានត្រឹមត្រូវ

1. នៅក្នុងឆ្នាំ1944 លោកឧត្តមសេនីយ៍បារាំង**សាលដឺហ្គោល**បង្កើតរដ្ឋាភិបាលបណ្ដោះអាសន្ន ។

2. ក្រោយសង្គ្រាមលោកលើកទី 2 ប្រទេសអាឡឺម៉ង់បែកជាពីរ គឺ **សាធារណរដ្ឋប្រជាធិបតេយ្យអាឡឺម៉ង់ឬអាឡឺម៉ង់ខាងកើត និងសហព័ន្ធអាឡឺម៉ង់ឬអាឡឺម៉ង់ខាងលិច។**

3.នៅឆ្នាំ1946 រដ្ឋធម្មនុញ្ញថ្មីរបស់សហព័ន្ធយូហ្គោស្លាវីបានផ្តល់ស្វ័យភាពដល់រដ្ឋទាំង 6 តែជាក់ស្តែងអំណាចក្នុងកណ្តាប់ដៃប្រធានាធិបតីទីតូនិងអ្នកដឹកនាំគណបក្សកុម្មុយនីស។

III. គូសភ្ជាប់ឈ្មោះប្រធានាធិបតីទៅឈ្មោះប្រទេស ។

| ឈ្មោះប្រធានាធិបតី | ឈ្មោះប្រទេស | ចម្លើយ |
|---|---|---|
| 1.កេណ្ណឌី<br>2.ឌុក្លាសហ្យូម<br>3.មីទែរ៉ង់<br>4.ទីតូ<br>5.ប្រេស្នែវ | ក.សហភាពសូវៀត<br>ខ.សហរដ្ឋអាមេរិប<br>គ.បារាំង<br>ឃ.អង់គ្លេស<br>ង.យូហ្គោស្លាវី | 1. →ខ<br>2. →ឃ<br>3. →គ<br>4. →ង<br>5. →ក |

IV. ចម្លើយ

1. កត្តាដែលជាប្រភពជំរុញឱ្យមានការកសាងប្រព័ន្ធដឹកនាំពិភពលោកតែមួយ(សកលភាវូបនីយកម្ម) មានដូចជា៖

➢ កម្លាំងចលករនៃប្រព័ន្ធសេដ្ឋកិច្ចសកលលោក ដែលជំរុញឱ្យកាន់តែលេចឡើងនូវអស្ថិរភាពន និងផលវិបាកចំពោះបញ្ហាផ្ទៃក្នុងប្រទេស និងទំនាក់ទំនងរវាងប្រទេសលើសកលលោក

- កំណើនយ៉ាងខ្លាំង នូវបំលាស់ប្តូទីកន្លែងរស់នៅរបស់ប្រជាពលរដ្ឋនៅលើសកលលោក
- ការរីកចម្រើនយ៉ាងខ្លាំង នូវប្រព័ន្ធទំនាក់ទំនងទូរគមនាគមន៍អន្តរជាតិ
- ការរីកសាយភាយយ៉ាងខ្លាំង នូវបច្ចេកវិទ្យាយោធាទំនើបដែលជានិច្ចកាលបានក្លាយជាឧបករណ៍នយោបាយសកលលោក
- បញ្ហារួមជាច្រើនបានកើតឡើង ដែលទាមទារឱ្យមានការសម្រេចចិត្តដោះស្រាយបញ្ហាទាំងនេះតាមរយៈថ្នាក់ដឹកនាំ រដ្ឋាភិបាល អង្គការអន្តរជាតិ និងសហគមអន្តរជាតិជាដើម។

2.បញ្ហាបរិស្ថានធម្មជាតិបានគំរាម កំហែងសកលលោក ដូចជា៖

- គ្រោះទឹកជំនន់
- ភាពរាំងស្ងួត
- ការឡើងកំដៅផែនដី
- ការបំពុលបរិយាកាស
- ការរលាយទឹកកក
- ការធ្វើឱ្យខូចស្រទាប់អូហ្សូន
- ភ្លៀងអាស៊ីត
- ធ្វើឱ្យពិភពលោកជួបនូវកង្វះស្បៀង
- ធ្វើឱ្យបាត់បង់ជីវចម្រុះដែលប៉ះពាល់ដល់ជីវិតមនុស្សសត្វ ។

3. បានជាក្រោយឆ្នាំ 1991 ប្រទេសឆេកូស្លូវ៉ាគីបែកជាពីរព្រោះក្រោយពីរបបកុំម្មុយនីសដួលរលំ មានការខ្វែងគំនិតគ្នារវាងអ្នកដឹកនាំឆែកនិងស្លូវ៉ាគីអំពីបញ្ហានយោបាយ និងសេដ្ឋកិច្ចដែល ជាឧបសគ្គក្នុងការបង្កើតរដ្ឋជម្មនុញ្ញ និងនាំឱ្យមានភាពយឺតយ៉ាវក្នុងកំណែទម្រង់សេដ្ឋកិច្ច ។

4. បានជាគេថា ប្រទេសប៉ូឡូញជាប្រភពនៃសង្គ្រាមលោកលើកទី2 ព្រោះប្រទេសប៉ូឡូញជាកន្លែងមហិចតារវាងមហាអំណាចជិតខាងគឺអាឡឺម៉ង់ និងសហភាពសូវៀតដែលចង់បែងចែកទឹកដីរបស់ប្រទេសប៉ូឡូញ ដោយចុះសន្ធិសញ្ញាជាសម្ងាត់។

## ជំពូកទី៧ ប្រវត្តិសាស្ត្រប្រទេសកម្ពុជា

### មេរៀនទី1 ប្រទេសកម្ពុជាក្រោមអាណាព្យាបាលបារាំង (1863-1953)

#### សំណួរ

1. តើបារាំងចូលមកគ្រប់គ្រងប្រទេសកម្ពុជា នៅពេលណា ? ដោយរបៀបណា ?
2. ហេតុដូចម្ដេចបានជាកិច្ចព្រមព្រៀងបារាំង-កម្ពុជា ឆ្នាំ1863 មានចរិតលក្ខណៈជាការដាក់ ប្រទេសកម្ពុជាក្រោមអាណាព្យាបាលបារាំង ?
3. តើកំណែទម្រង់ឆ្នាំ1877និង1884 មានកម្មវិធីដូចម្ដេចខ្លះ ?
4. តើបារាំងប្រើមធ្យោបាយដូចម្ដេច ដើម្បីសម្រេចទិសដៅនយោបាយកំណែទម្រង់របស់ខ្លួន ?
5. តើកំណែទម្រង់បារាំងបាននាំមកដល់សង្គមខ្មែរនូវអ្វីខ្លះ ?
6. តើចលនាតស៊ូដើម្បីឯករាជ្យជាតិ ក្នុងប្រទេសកម្ពុជាបានប្រព្រឹត្តទៅបែបណា ?
7. តើសន្និសីទក្រុងសឺណែវឆ្នាំ 1954បានអនុម័តលើកិច្ចព្រមព្រៀងអ្វីខ្លះសម្រាប់កម្ពុជា ?
8. តើវត្តមានបារាំងនៅលើទឹកដីខ្មែរ ផ្ដល់ផលវិជ្ជមាននិងអវិជ្ជមានដូចម្ដេចខ្លះ ?

## ចម្លើយ

1. បារាំងចូលមកគ្រប់គ្រងប្រទេសកម្ពុជានៅពេល ដែលបារាំងបរាជ័យ ក្នុងការធ្វើដំណើរទៅប្រទេសចិនប៉ែកខាងត្បូងតាម រយៈទន្លេមេគង្គ ពេលនោះបារាំងមានការចាប់អារម្មណ៍យ៉ាងខ្លាំងចំពោះធនធានដែលមាននៅក្នុងប្រទេសកម្ពុជា ដូចជាទន្លេដែល ជាប្រភពគមនាគមយ៉ាងសំខាន់សម្រាប់ដឹកជញ្ជូនផលិតផល កសិកម្មទៅកាន់ទីផ្សារនៅអឺរ៉ុប មានដីមានដីជាតិសម្រាប់ដំនាំផ្សេងៗ មានធនធានរ៉ែ និងព្រៃឈើដ៏សំបូរបែប។
   - ❖ បារាំងចូលមកគ្រប់គ្រងប្រទេសកម្ពុជា ដោយចុះសន្ធិសញ្ញាជាមួយព្រះនរោត្តមដើម្បីគ្រប់គ្រងប្រទេសកម្ពុជា។
2. បានជាកិច្ចព្រមព្រៀងបារាំង-កម្ពុជា ឆ្នាំ1863មានចរិតលក្ខណៈជាការដាក់ប្រទេសកម្ពុជា ក្រោមអាណាព្យាបាលបារាំង ព្រោះខ្លឹមសារនៃសន្ធិសញ្ញានេះ មានចែញអំពីការជួយការពារប្រទេសកម្ពុជា ដោយរក្សាទឹកដីមិនឱ្យមានការបាត់បង់តទៅទៀត។
3. កំណែទម្រង់ឆ្នាំ1877និង1884 មានកម្មវិធីដូចជា
   - ❖ កំណែទម្រង់ឆ្នាំ1877 មានកម្មវិធីដូចជា៖

➢ មានកម្មវិធីនយោបាយថ្មីមួយ ដើម្បីកាតើបន្ថយអំណាចស្តេចត្រាញ់ មន្ត្រីសកក្តិភូមិ និងលប់បំបាត់វណ្ណៈខ្ញុំគេ បង្កើតចំនួន

ម្ចាស់កម្មសិទ្ធិ ដែលជាកម្លាំងចលករជួយជំរុញកម្មវិធីកំណែទម្រង់បារាំងឱ្យបានជោគជ័យ

-កម្មវិធីបង្កើតតុលាការជាន់ខ្ពស់គ្រប់គ្រងលើតុលាការមូលដ្ឋាន បង្កើតប្រព័ន្ធពន្ធដារថ្មី

-បារាំងបានធ្វើឱ្យប្រទេសសៀម ទទួលការគ្រប់គ្រង់របស់បារាំងលើកម្ពុជា

-ចរចាអំពីបញ្ហាព្រំដែនរវាងប្រទេសកម្ពុជានិងសៀម

-ឆ្នាំ1908 បារាំងបានធ្វើផែនទីមួយមានឈ្មោះថាផែនទីដងរែក ដែលទទួលស្គាល់ដោយតំណាងបារាំង-សៀមនិងនៅលើ ឆាកអន្តរជាតិរហូតដល់សព្វថ្ងៃ។

❖កំណែទម្រង់ឆ្នាំ 1884 មានកម្មវិធីដូចជា៖

-បារាំងបានដាក់ប្រទេសកម្ពុជាក្រោមការគ្រប់គ្រង់ផ្ទាល់ របស់ខ្លួន។

.មធ្យោបាយបារាំង ដើម្បីសម្រេចទិសដៅនយោបាយកំណែទម្រង់របស់ខ្លួនគឺ ៖

❖ ការប្រើប្រាស់លុយផ្តល់ឱ្យមន្ត្រីខ្មែរដើម្បីទម្លុះទម្លាយគម្រោងការរបស់គេ។

5.កំណែទម្រង់បារាំងបាននាំមកដល់សង្គមខ្មែរដូចជា៖
➢ធ្វើឱ្យសង្គមខ្មែរប្រែមុខមាត់ថ្មី
➢របៀបគ្រប់គ្រងរដ្ឋបាលថ្មី
➢លុបបំបាត់របបទាសភាព
➢បង្កើតច្បាប់
➢បង្កើតកម្មសិទ្ធិដីធ្លី
➢ផ្លាស់ប្តូរប្រពៃណីវប្បធម៌។
6.ចលនាតស៊ូដើម្បីឯករាជ្យជាតិ ក្នុងប្រទេសកម្ពុជាបានប្រព្រឹត្តិទៅដោយចែកជាពីរផ្នែកគឺ
➢ការតស៊ូដោយអាវុធ ដឹកនាំដោយកម្លាំងនៃចលនាតស៊ូខ្មែរឥស្សរៈដែលមានការជួយគាំទ្រពីសំណាក់កងកម្លាំងវៀត មិញ
➢ការតស៊ូដោយសន្តិវិធីដឹកនាំដោយសម្តេចព្រះ នរោត្តម សីហនុ(នយោបាយការទូត)។
7.សន្និសីទក្រុងសឺណែវឆ្នាំ 1954បានអនុម័តលើកិច្ចព្រមព្រៀងសម្រាប់កម្ពុជាដូចជា៖
➢កិច្ចព្រមព្រៀងស្តីពី ការបញ្ឈប់បទឈប់បាញ់នៅក្នុងប្រទេសកម្ពុជា
➢សេចក្តីប្រកាសរបស់រាជរដ្ឋាភិបាលកម្ពុជាអំពីសិទ្ធិ របស់ប្រជាពលរដ្ឋនិងការបោះឆ្នោតរដ្ឋាភិបាលកម្ពុជាទាក់ទងនឹង សម្ព័ន្ធ

ភាពយោធា ការតាំងមូលដ្ឋានទ័ពបរទេស និងការជួយឧបត្ថម្ភកម្លាំងយោធាពីបរទេស

- សេចក្តីប្រកាសរបស់រដ្ឋាភិបាលបារាំង ស្តីពីការដកកងទ័ពបារាំងចេញពីទឹកដីប្រទេសឥណ្ឌូចិន និងគោរពដល់ឯករាជ្យអធិបតេយ្យភាពនៃប្រទេសកម្ពុជានៅក្នុងឥណ្ឌូចិន
- សេចក្តីថ្លែងការណ៍របស់សន្និសីទទាក់ទងនឹងកិច្ចព្រមព្រៀងសឺណែវ

3. វត្តមានបារាំងនៅលើទឹកដីខ្មែរផ្តល់ផលវិជ្ជមាន និងអវិជ្ជមានដូចជា៖

❖ **ផលវិជ្ជមាន**

- ជួយសិក្សាស្រាវជ្រាវអំពីអំពីវប្បធម៌ខ្មែរនិងជួសជុលប្រាសាទបុរាណខ្មែរ
- ជួយទាមទាយកខេត្តមួយចំនួន ពីសៀមមកឱ្យខ្មែរវិញដូចជាបាត់ដំបង និងមហានគរតាមរយៈសន្និសញ្ញា បារាំងសៀមថ្ងៃទី 23 ខែ មីនា ឆ្នាំ1907
- នៅឆ្នាំ 1904 ក្រោមការគាប់សង្កត់របស់បារាំងសៀមបានប្រគល់ខេត្តម្លូព្រៃ ទន្លេពៅ និង ខេត្តកោះកុងមកឱ្យខ្មែរវិញ
- ជួយលើកស្ទួយវិស័យវប្បធម៌ខ្មែរ ជួយពង្រើងវិស័យអប់រំ ។

- វិស័យសេដ្ឋកិច្ច មានការកសិកម្ម ឧស្សាហកម្ម(កៅ ក្រចៅ ថ្នាំជក់ ។
- ជួយលើកស្ទួយជីវភាពកម្មករ និងបង្កើតមន្ទីពេទ្យដើម្បីព្យា ល ជំងឺកម្មករ
- កសាងគមនាគមស្ពាន ថ្នល់ ផ្លូវរថភ្លើង។

❖ **ផលអវិជ្ជមាន**

- ធ្វើឱ្យសង្គមខ្មែរកាន់តែក្រីក្រឡើង
- ធ្វើឱ្យប្រជាពលរដ្ឋខ្មែរ ស្លាប់នៅក្នុងសង្គ្រាមលោកលើកទី និងទី2
- ធ្វើឱ្យខ្មែរបាត់បង់វត្ថុកេតនភណ្ឌ
- បាត់បង់ទឹកដីកម្ពុជាក្រោម និងតំបន់ជាឡាត់ដោយកា ឱ្យយួន ។
- ខេត្តត្រាចត្រូវធ្លាក់ក្នុងកណ្ដាប់ដៃសៀម។

## មេរៀនទី2 របបសង្គមរាស្ត្រនិយម(1955-1970)

### សំណួរ

1. ហេតុដូចម្តេចបានជាសម្តេចព្រះ នរោត្តម សីហនុ បានបង្កើតអង្គការនយោបាយ"សង្គមរាស្ត្រនិយម" ?
2. ចូររៀបរាប់អំពី"សមាជជាតិ"។
3. ហេតុដូចម្តេចបានជាមានការតែងតាំងសម្តេចព្រះ នរោត្តម សីហនុជាព្រះប្រមុខរដ្ឋ ?
4. ចូររៀបរាប់អំពីសមិទ្ធផលសង្គមរាស្ត្រនិយម ។
5. ចូររៀបរាប់អំពីនយោបាយអព្យាក្រឹត និងផលវិបាកនៃការប្រកាន់នយោបាយអព្យាក្រឹត ?

### ចម្លើយ

1. បានជាសម្តេចព្រះ នរោត្តម សីហនុ បានបង្កើតអង្គការនយោបាយ"សង្គមរាស្ត្រនិយម" ពីព្រោះ

- ដើម្បីបង្រួបបង្រួមជាតិ
- ដើម្បីកសាងជាតិឱ្យរីកចម្រើន
- ដើម្បីឱ្យព្រះអង្គមានអំណាចក្នុងការកសាងប្រទេស។

2. ចូររៀបរាប់អំពី"សមាជជាតិ"៖

នៅថ្ងៃទី25 ខែកញ្ញា ឆ្នាំ 1955 អង្គការសង្គមរាស្ត្រនិយមបានរៀបចំសមាជដែលពេលនោះ មានការចូលរួមពីសំណាក់មហាជន

គ្រប់ស្រទាប់ រួមទាំងតំណាងគណបក្សផ្សេងៗទៀត។ សមាជ
បានរៀបចំ និងដឹកនាំដោយគណៈកម្មាធិការកណ្ដាលនៃអង្គ
សង្គមរាស្ត្រនិយម ដែលមានសម្ដេចព្រះនរោត្តមសីហនុជាប្រ
ប្រធាន។សមាជជាតិសម្រេចបានសមិទ្ធផលជាច្រើនដូចជា
ប្រឆាំងនឹងអំពើពុករលួយ ការកំណត់ភាសាខ្មែរជាភាសាផ្លូវក
សភាតំណាងរាស្ត្រមានសិទ្ធិចូលរួម ក្នុងការកែលម្អសកម្មភាព
ភិបាលនិងទាមទារឱ្យដាក់ទណ្ឌកម្មទៅលើមន្ត្រីរាជការណាដែល
អសកម្មជាដើម។ នៅទីបំផុតត្រូវបានសភាអនុម័តឱ្យក្លាយជាស្
ប័នរដ្ឋ បើយោងតាមរដ្ឋធម្មនុញ្ញនៅសម័យនោះ"សមាជគឺជាស្
ប័ននយោបាយរដ្ឋ ដែលទាមទារឱ្យមានជំនួបប្រជាពលរដ្ឋជាមួ
នឹងមន្ត្រីរដ្ឋាភិបាលដើម្បីពិភាក្សាអំពីប្រយោជន៍ជាតិរួម។

3.បានជាមានការតែងតាំងសម្ដេចព្រះ នរោត្តម សីហនុជាប្រ
ប្រមុខរដ្ឋ ព្រោះដោយសារ ៖

- ពុំមានស្ដេចសោយរាជបន្តដោយសារព្រះមហាក្សត្រនរោត្តម សុរាម្រឹតចូលទីវង្គត
- មានការគាំទ្រពីប្រជាពលរដ្ឋខ្មែរដែលគាំទ្រព្រះអង្គ។

4.រៀបរាប់អំពីសមិទ្ធផលសង្គមរាស្ត្រនិយមមានដូចជា៖

❖វិស័យកសិកម្ម ៖

➢ ផលស្រូវនៅឆ្នាំ1955 ទទួលបាន1 484 000 តោន ហើយនៅឆ្នាំ1968 ទទួលបាន3 25 000 តោន ។

➢ ផលកប្បាសនៅឆ្នាំ1964 ទទួលបាន 5 000 តោនក្នុងនោះ 200 តោនបម្រើរោងចក្រតម្បាញក្នុងស្រុក ហើយ 3 000 តោនទៀតនាំចេញទៅក្រៅប្រទេស។

➢ ផលចិញ្ចឹមសត្វ ស្លាបសត្វ, គោនៅឆ្នាំ 1965 មាន620 000 ក្បាល ,ជ្រូកនៅឆ្នាំ 1965 មាន 980 000។

➢ រាជរដ្ឋាភិបាលបង្កើតរុក្ខទិវានៅគ្រប់ខេត្ត។

➢ វិស័យនេសាទមានការរីកចម្រើនគួរឱ្យកត់សម្គាល់ និងអាចបម្រើជីវភាពប្រជាពលរដ្ឋកម្ពុជាក្នុង ប្រទេសនិងនាំចេញទៅលក់នៅបរទេសទៀត ។

➢ ក្រៅពីនេះរដ្ឋាភិបាលបានបង្កើតក្រុមបសុពេទ្យ ដើម្បីព្យាបាលជំងឺសត្វ។

❖ **វិស័យគមនាគមន៍**

➢ ឆ្នាំ1954ពង្រីកកំពង់ផែភ្នំពេញនិងកសាងកំពង់ផែ ទឹកប្រៃនៅក្រុងព្រះសីហនុ

➢ នៅឆ្នាំ1956 កសាងផ្លូវជាតិលេខ 4 ពីភ្នំពេញទៅក្រុងព្រះសីហនុប្រវែង 226 Km

➢ ពង្រីកអាកាសយានដ្ឋានអន្តរជាតិពោធិ៍ ចិនតុងនិងកសាងអាកាសយានដ្ឋានអន្តរជាតិខេត្តសៀម រាប

➢ ឆ្នាំ 1960 កសាងផ្លូវរថភ្លើងភ្នំ-ក្រុងព្រះសីហនុប្រវែង 270Km

➢ កសាងស្ពានជ្រោយចង្វា(មិត្តភាពកម្ពុជា-ជប៉ុន) ឆ្លងទន្លេសាប

➢ ឆ្នាំ1961ព្រះរាជាណាចក្រកម្ពុជាបានភ្ជាប់ខ្សែទូរស័ព្ទជាមួយក្រុងតូកក្យូ សាន់ហ្វ្រាន់ស៊ីស្កូ អូសាកា ....។

❖ **វិស័យពាណិជ្ជកម្ម**

➢ ក្រុមហ៊ុនពាណិជ្ជកម្មធំៗរបស់បារាំង និងសាខាក្រុមហ៊ុនរបស់សហរដ្ឋអាមេរិចបានដាក់វិនិយោគទុននៅ កម្ពុជា។

➢ 1956 ការប្រើប្រាស់ឥណទានខាងពាណិជ្ជកម្មក្រៅប្រទេសកម្ពុជាបានប្រគួតប្រជែងជាមួយ បារាំង អាមេរិចអង់គ្លេស និងជប៉ុន

➢ ឆ្នាំ1963 រដ្ឋាភិបាលបានបង្កើតក្រុមហ៊ុនពាណិជ្ជកម្មថ្មីឈ្មោះ "ក្រុមហ៊ុនអាហារណៃនីហារណៃ"

❖ឆ្នាំ1964 រាជរដ្ឋាភិបាលបានបង្កើតក្រុមហ៊ុនពាណិជ្ជកម្មរដ្ឋនិងឯកជនពីរគឺក្រុមហ៊ុនខ្មែរនៃការ ទិញផលិតផល

កសិកម្ម  និងក្រុមហ៊ុនជាតិនៃការចែករំលែកទំនិញនាំចូល។

❖ឧស្សាហកម្ម៖

រាជរដ្ឋាភិបាលបានកសាងរោងចក្រជាច្រើនដូចជា៖

- ➢ រោងចក្រវាយនភ័ណ្ឌ(កំពង់ចាម)
- ➢ រោងចក្រក្ដាបន្ទះដីឥដ្ឋ
- ➢ រោងចក្រកែវនៅចំការដូង(កណ្ដាល)
- ➢ រោងចក្រក្រដាសឆ្លូង(ក្រចេះ)
- ➢ រោងចក្រស៊ីម៉ង់ចក្រីទីង(កំពត)
- ➢ រោងចក្រក្រចៅដូនទាវ(បាត់ដំបង)
- ➢ រោងចក្រស្ករសកំពង់ត្រាំ(កំពង់ស្ពឺ)
- ➢ រោងចក្រស្រាបៀនិងដំឡើងត្រាក់ទ័រ(ក្រុងព្រះសីហនុ)។

❖វិស័យវប្បធម៌៖

➢ រាជរដ្ឋាភិបាលបានយកចិត្តទុកដាក់លើវិស័យសិក្សាធិការជាតិដោយបណ្ដោះបណ្ដាលគ្រូបង្រៀន  កសាងសាលារៀនចាប់ពីបឋមសិក្សាដល់សាកលវិទ្យាល័យ និងបានបញ្ជូននិស្សិតខ្មែរឱ្យទៅសិក្សានៅបរទេសជាពិសេសប្រទេសបារាំង។

➢ លើកស្ទួយវិស័យកីឡា

➢ យកចិត្តទុកដាក់លើវិស័យសាសនាដោយបាន បង្កើតពុទ្ធិកបឋមសិក្សាដល់ពុទ្ធិកមហាវិទ្យាល័យ។

❖វិស័យសង្គមកិច្ច

➢មានការកសាងមន្ទីពេទ្យគ្រប់ខេត្តក្រុង

➢ការអភិវឌ្ឍជនបទដូចជាការរក្សាអនាម័យតាម លំនៅឋាន ជីកអណ្តូងទឹកសង់ផ្ទះ ជីកស្រះ ឱ្យប្រជារាស្រ្ត ។

➢បង្កើតមជ្ឈមណ្ឌលអប់រំស្ត្រីពេស្យានៅទួលគកនិង ផ្តល់សិទ្ធិឱ្យស្ត្រីឈរឈ្មោះបោះឆ្នោតនិងមានសិទ្ធិបោះឆ្នោត

5.រៀបរាប់អំពីនយោបាយអព្យាក្រឹត

នយោបាយអព្យាក្រឹតនៅក្នុងកម្មវិធីនយោបាយការបរទេសដំបូង ត្រូវបានកំណត់នៅក្នុងសេចក្តីសម្រេចចិត្តនៃសន្និសីទសឺណែវឆ្នាំ1954 ។ សេចក្តីសម្រេចនេះជាការទាមទាររបស់ចិន និង សហភាពសូវៀតដើម្បីបញ្ចៀសមិនឱ្យសហរដ្ឋអាមេរិចកសាងមូលដ្ឋានទ័ពនៅកម្ពុជា។ ។នៅថ្ងៃទី 14ខែធ្នូ ឆ្នាំ 1955 ប្រទេសកម្ពុជាបាន ចូលជាសមាជិកនៃអង្គការសហប្រជាជាតិដែលនៅទីនោះតំណាង រដ្ឋាភិបាលកម្ពុជាបានធ្វើសេចក្តីប្រកាសអំពីការប្រឹងប្រែងរបស់ ខ្លួនក្នុងការដើរលើមាគ៌ានយោបាយអព្យាក្រឹត។

❖ ផលវិបាកនៃការប្រកាន់នយោបាយអព្យាក្រឹត

➢ ធ្វើឱ្យប្រទេសកម្ពុជាមានសន្តិភាព ក្នុងខណៈដែលប្រទេសជិតខាងមានសង្គ្រាម

➢ មិនអាចមានលទ្ធភាពការពារខ្លួនឯងទប់ទល់ និងការលុកលុយពីសំណាក់ប្រទេសមហាអំណាចក្នុងស្ថានភាពសង្គ្រាមត្រជាក់។

## មេរៀនទី3 សាធារណរដ្ឋខ្មែរ(1970-1975)

### សំណួរ

1. ហេតុដូចម្ដេចបានជាលេចឡើងនូវរបបសាធារណរដ្ឋខ្មែរ ?
2. ហេតុអ្វីបានជាគេចាត់ទុកការបោះឆ្នោតសភាថ្ងៃទី18 ខែមីនា ឆ្នាំ1970 ជាការធ្វើរដ្ឋប្រហារទម្លាក់សម្ដេចព្រះ នរោត្តម សីហនុ ?
3. តើលោកសេនាប្រមុខលន់ណល់ ដោះស្រាយជនបទបានដែរឬទេ ?ព្រោះអ្វី ?
4. តើពួកខ្មែរក្រហមមានសកម្មភាពយ៉ាងណា ដើម្បីអូសទាញប្រជាជនខ្មែរឱ្យគាំទ្រពួកគេ ?
5. តើមូលហេតុអ្វីដែលធ្វើឱ្យរបបសាធារណរដ្ឋខ្មែរដួលរលំ ?

### ចម្លើយ

1. បានជាលេចឡើងនូវរបបសាធារណរដ្ឋខ្មែរ ព្រោះដោយសារ៖

❖ការពង្រីកមនោគមវិជ្ជារបស់ពួកប្រទេសមហាអំណាចទាំងពីរ

❖ការធ្វើរដ្ឋប្រហារទំលាក់សម្ដេច នរោត្តម សីហនុ ។

2. បានជាគេចាត់ទុកការបោះឆ្នោតសភាថ្ងៃទី18 ខែមីនា ឆ្នាំ 1970 ជាការធ្វើរដ្ឋប្រហារទម្លាក់សម្ដេចព្រះ នរោត្តម សីហនុ ព្រោះការបោះឆ្នោតបានប្រព្រឹត្តទៅដោយមិនស្របច្បាប់ដោយយករដ្ឋសភាធ្វើជាឧបករណ៍ពង្រឹងអំណាច។

3.លោកសេនាប្រមុខលន់ណល់ មិនអាចដោះស្រាយជនបទបានទេ ព្រោះផ្លូវទៅជនបទត្រូវបានកាត់ផ្ដាច់ដោយពួកកុម្មុយនីសអស់ទៅហើយ ហើយម៉្យាងទៀតនៅក្នុងជួរដ្ឋាភិបាលពោពេញដោយអំពើពុករលួយ។

4.សកម្មភាពរបស់ពួកខ្មែរក្រហម ដើម្បីអូសទាញប្រជាជនខ្មែរឱ្យគាំទ្រពួកគេ ៖

➢ប្រមូលប្រជនឱ្យចូលរួមក្នុងចលនាតស៊ូ

➢ផ្សព្វផ្សាយមនោគមវិជ្ជាដល់ពួកនិស្សិតនៅទីក្រុងភ្នំពេញ

➢ប្រឆាំងជាមួយពួកមូលធនដែលពុករលួយ

➢ថានឹងធ្វើឱ្យប្រជាជនមានភាពស្មើរគ្នា គ្មានការគេងប្រវ័ញ្ច។

5.មូលហេតុដែលធ្វើឱ្យរបបសាធារណរដ្ឋខ្មែរដួលរលំ ៖

➢ពោរពេញដោយអំពើពុករលួយ

➢មិនអាចដោះស្រាយបញ្ហានៅជនបទបាន

➢លែងទទួលបានជំនួយពី អាមេរិច។

# មេរៀនទី4 កម្ពុជាប្រជាធិបតេយ្យ(1975-1979)

## សំណួរ

1. តើពួកខ្មែរក្រហមមានគោលនយោបាយដូចម្ដេចក្រោយថ្ងៃ17 មេសា1975 ?
2. ហេតុអ្វីបានជាពួកខ្មែរក្រហមជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញនិងទីប្រជុំជននានា ?
3. តើដូចម្ដេចហៅថាអង្គការ( ខ្មែរក្រហម ) ?
4. ចូររៀបរាប់ពីរចនាសម្ព័ន្ធគ្រប់គ្រងរដ្ឋនិងមជ្ឈិមបក្សកុំមុយនីសឆ្នាំ1976?
5. តើពួកខ្មែរក្រហមបែងចែកប្រទេសកម្ពុជាប៉ុន្មានភូមិភាគ? អ្វីខ្លះ ?
6. តើជីវិតប្រជាជនខ្មែរក្នុងរបបកម្ពុជាប្រជាធិបតេយ្យជួបប្រទះនឹងបញ្ហាអ្វីខ្លះ ?
7. តើមូលហេតុអ្វីបានជារបបកម្ពុជាប្រជាធិបតេយ្យដួលរលំ ?

# ចម្លើយ

1. ពួកខ្មែរក្រហមមានគោលនយោបាយក្រោយថ្ងៃ 17 មេសា 1975 ដូចជា ៖

➢ ជម្លៀសប្រជាជនឱ្យចេញពីទីក្រុងភ្នំពេញទាំងអស់

➢ លប់បំបាត់ទីផ្សារ

➢ ផ្សឹកលោកសង្ឃក្នុងសំណាក់ព្រះពុទ្ធសាសនាទាំងអស់ ហើយឱ្យទៅធ្វើស្រែ ចំការ និង នៅតំបន់មូលដ្ឋានជនបទ

➢ ប្រហាជីវិតមេដឹកនាំបេបលន់ នល់

➢ លប់បំបាត់ការប្រើប្រាស់និងចរាចរណ៍រូបិយប័ណ្ណ

➢ បង្កើតសហករណ៍កំរិតខ្ពស់ទូទាំងប្រទេស

➢ បណ្តេញជនជាតិភាគតិចវៀតណាមឱ្យចេញទាំងអស់

➢ បញ្ជូនទ័ពទៅតាមព្រំប្រទល់ជាពិសេសព្រំប្រទល់វៀត ណាម។

2. បានជាពួកខ្មែរក្រហមជម្លៀសប្រជាជនចេញពីទីក្រុង ភ្នំពេញ និងទីប្រជុំជននានា ពីព្រោះ ៖

➢ ទាក់ទងនឹងបញ្ហាស្បៀងមិនអាចផ្គត់ផ្គង់ប្រជាជននៅទីប្រជុំជន ក៏ដូចជាក្រុង នៅឯជនបទមានស្បៀងគ្រប់គ្រាន់

➢ ការលំបាកក្នុងការគ្រប់គ្រងប្រជាជនរាប់លាននាក់ប្រឆាំងបដិវត្តន៍

➢អ្នកដឹកនាំបក្សកុម្មុយនីសមានការភ័យខ្លាចចំពោះសន្តិសុខផ្ទាល់ខ្លួន

3.ដែលហៅថាអង្គការ(ខ្មែរក្រហម) គឺជាពាក្យមួយម៉ាត់ដែលគ្របដណ្តប់ទាំងបកក្សកុំម៉ុយនីស ទាំងអង្គការនីតិប្បញ្ញត្តិ នីតិប្រតិបត្តិនិងតុលាការ។

4.រៀបរាប់ពីរចនាសម្ព័ន្ធគ្រប់គ្រងរដ្ឋនិងមជ្ឈិមបក្សកុំមុយនីសឆ្នាំ1976

❖រចនាសម្ព័ន្ធគ្រប់គ្រងរដ្ឋ



❖រចនាគ្រប់គ្រងមជ្ឈិមបក្សកុំម៉ុយនីស




5.ពួកខ្មែរក្រហមបែងចែកប្រទេសកម្ពុជា7ភូមិភាគគឺ ៖

➢ភូមិភាគបូព៌ា( ភូមិភាគ 203 )

➢ភូមិភាគនិរតី( ភូមិភាគ 405 )

➢ភូមិភាគឧត្តរ( ភូមិភាគ 303 )

➢ភូមិភាគពាយ័ព្យ( ភូមិភាគ 560 )

➢ភូមិភាគបស្ចិម( ភូមិភាគ 401 )

➢ភូមិភាគឦសាន( ភូមិភាគ108 )

➢ភូមិភាគពិសេស

6.ប្រជាជនខ្មែរក្នុងរបបកម្ពុជាប្រជាធិបតេយ្យជួបប្រទះនឹង ៖

➢ការពុំមានអាហារហូបគ្រប់គ្រាន់

➢ការធ្វើទារុណ្ណកម្មលើរូងរាងកាយ និងទារុណ្ណកម្មផ្សេងៗទៀត

➢គ្មានសិទ្ធិសេរីភាពអ្វីទាំងអស់

➢ ការឱ្យធ្វើការលើសកម្លាំងគ្មានឈប់សម្រាក
➢ ការមិនឱ្យប្រជាជនគោរពប្រពៃណីវប្បធម៌
➢ ការគ្មានការអប់រំបានជ្រៅជ្រះ។

7.បានជារបបកម្ពុជាប្រជាធិបតេយ្យដួលរលំ ដោយសារៈ
➢ ប្រជាជនស្អប់របបប៉ុល ពត
➢ វិសុទ្ធកម្ម( ការចំរាញយកមនុស្សបដិវត្តន៍បរិសុទ្ធ )
➢ ការធ្វើសង្គ្រាមជាមួយប្រទេសវៀតណាម។

## មេរៀនទី5 សាធារណរដ្ឋប្រជាមានិតកម្ពុជានិងរដ្ឋកម្ពុជា

(1979-1993)

### សំណួរ

1. តើថ្ងៃទី7ខែមករាឆ្នាំ1979 បញ្ជាក់ពីកាលបរិច្ឆេទអ្វី ?
2. ហេតុអ្វីបានជាមានថ្ងៃទី7 ខែមករាឆ្នាំ1979 ?
3. តើកត្តាអ្វីខ្លះនាំឱ្យថ្ងៃទី7 ខែមករាឆ្នាំ1979 មានជ័យជំនះលើរបបប្រល័យពូជសាសន៍ ?
4. ហេតុអ្វីបានគេបង្កើតឱ្យមានក្រុមសាមគ្គីបង្កបង្កើនផល ? ចូរពន្យល់ពីការបែងចែកកម្លាំងពលកម្ម ?
5. ហេតុអ្វីបានជារដ្ឋាភិបាលកម្ពុជា បង្កើតនយោបាយបង្រួបបង្រួមជាតិ ?
6. តើកិច្ចចរចាក្រុងប៉ារីសថ្ងៃទី23ខែតុលា ឆ្នាំ1991ផ្តល់សារៈសំខាន់អ្វីខ្លះដល់កម្ពុជា ?

### ចម្លើយ

1. ថ្ងៃទី7ខែមករាឆ្នាំ1979 បញ្ជាក់ពីកាលបរិច្ឆេទដែលកងកម្លាំងប្រដាប់អាវុធរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជាបានរំដោះប្រជា ពលរដ្ឋពីរបបប្រល័យពូជសាសន៍ឬជាថ្ងៃដែលប្រជាជនខ្មែរបាន រួចផុតពីគ្រោះប្រល័យពូជសាសន៍។

2.បានជាមានថ្ងៃទី7 ខែមករាឆ្នាំ1979 ព្រោះដោយសារតែមាន រណសិរ្សសាមគ្គីសង្គ្រោះជាតិដែលបានបង្កើតនៅ ថ្ងៃទី2 ធ្នូ ឆ្នាំ 1978 ។

3.កត្តាដែលនាំឱ្យថ្ងៃទី7 ខែមករាឆ្នាំ1979 មានជ័យជំនះលើរបបប្រល័យពូជសាសន៍ គឺ៖

➢ កត្តាមានជំនួយពីកងទ័ពវៀតណាម

➢ ការចូមរួមរបស់ប្រជាជនកម្ពុជា។

4.បានគេបង្កើតឱ្យមានក្រុមសាមគ្គីបង្កបង្កើនផលព្រោះដើម្បីជួយសម្រាលបន្ទុក ស្ត្រីមេម៉ាយ ក្មេងកំព្រា មនុស្សចាស់ជរាដែល ពួកគេពុំមានកម្លាំងពលកម្ម និងឧបករណ៍ប្រើប្រាស់គ្រប់គ្រាន់ បន្ទាប់ពីសង្គ្រាមបានបញ្ចប់។

❖ ការបែងចែកកម្លាំងពលកម្ម ៖

នៅតាមភូមិនីមួយៗគេបែងចែកជាក្រុម ក្នុងមួយក្រុមមានប្រមាណជា10 គ្រួសារ ។ រីឯចំនួនសមាជិកក្នុងក្រុមប្រែប្រួលទៅតាមចំនួនសមាជិកគ្រួសារ( កូនតិចឬច្រើន )។

5. បានជារដ្ឋាភិបាលកម្ពុជា បង្កើតនយោបាយបង្រួបបង្រួមជាតិពីព្រោះ

➢ ដើម្បីបញ្ចប់ជម្លោះរវាងក្រុមកម្ពុជាប្រជាធិបតេយ្យ ដែលរត់ចូលព្រៃធ្វើសង្គ្រាមប្រឆាំងនិងរបបរដ្ឋកម្ពុជា ហើយបង្ករអសន្តិសុខដល់ប្រជាពលរដ្ឋនិងសង្គមកម្ពុជា

➢ ដើម្បីផ្សះផ្សារជាតិនិងស្តាប្រទេស

6. កិច្ចចរចាក្រុងប៉ារីសថ្ងៃទី 23 ខែតុលា ឆ្នាំ 1991ផ្តល់សារៈសំខាន់ដល់កម្ពុជា ដូចជា៖

➢ ធ្វើឱ្យប្រទេសកម្ពុជាមានសន្តិភាព

➢ រៀបចំការបោះឆ្នោតនៅកម្ពុជា

➢ ដោះស្រាយបញ្ចប់សង្គ្រាមនៅកម្ពុជា។

# សំណួរបញ្ចប់ជំពូកទី2

I. ចូរគូសសញ្ញា✓ក្នុងប្រអប់ចម្លើយត្រឹមត្រូវ

1. តើបារាំងចូលគ្រប់គ្រងប្រទេសកម្ពុជាដំបូងក្នុងរជ្ជកាលព្រះរាជាខ្មែរអង្គណា ?

☐ក. អង្គដួង ☐ខ. នរោត្តម

☐គ. ស៊ីសុវត្ថិ ☐ឃ. សីហនុ

2. តើសង្គមរាស្ត្រនិយមបានចាប់ផ្តើមឡើងនៅឆ្នាំណា ?

☐ក.1952 ☐ខ.1953

☐គ.1954 ☐ឃ.1955

3. តើនរណាដឹកនាំរបបកម្ពុជាប្រជាធិបតេយ្យ(មេធំជាងគេ)

☐ក. ប៉ុលពត ☐ខ. អៀងសារី

☐គ. ខៀវសំផន ☐ឃ. សុនសេន

II. **ចូរបំពេញឈ្លោះខាងក្រោមឱ្យបានត្រឹមត្រូវ**

1. កិច្ចចរចាសន្តិភាពនាទីក្រុងផែអង់តាជីន័រថ្ងៃទី......... ខែ... ......ឆ្នាំ.........។

2. រដ្ឋប្រហារថ្ងៃទី18ខែមីនាឆ្នាំ1970ធ្វើឡើងដោយ..........និង ...................។

3. ពួកខ្មែរក្រហមបានចូលកាន់កាប់ប្រទេសកម្ពុជានៅ......ខែ. ......ឆ្នាំ............។

## I. ចូរគូសភ្ជាប់ឈ្មោះអ្នកដឹកនាំទៅឈ្មោះប្រទេស

| ឈ្មោះអ្នកដឹកនាំ | ឈ្មោះរបប | ចម្លើយ |
|---|---|---|
| 1.ប៉ុលពត | ក. សាធារណរដ្ឋប្រជាមានិតកម្ពុជា | 1.→ |
| 2.នរោត្តមសីហនុ | ខ. សង្គមរាស្ត្រនិយម | 2.→ |
| 3.លន់ណល់ | គ. កម្ពុជាប្រជាធិបតេយ្យ | 3.→ |
| 4.ហ៊ុនសែន | ឃ. សាធារណរដ្ឋខ្មែរ | 4.→ |
| 5.ហេងសំរិន | ង. ព្រះរាជាណាចក្រកម្ពុជា | 5.→ |

## V. សំណួរត្រិះរិះ

1. តើលទ្ធផលវិជ្ជមាននិងអវិជ្ជមាននៃរបបអាណានិគមបារាំងមកលើកម្ពុជាមានអ្វីខ្លះ ?
2. ចូររៀបរាប់ពីសមិទ្ធផលសង្គមរាស្ត្រនិមយ ។
3. តើផលវិបាកនៃសង្គ្រាមស៊ីវិលក្នុងរបបលន់ណល់បានធ្វើឱ្យសង្គមខ្មែរជួបប្រទះអ្វីខ្លះ ?
4. តើមូលហេតុអ្វីបានជារបបកម្ពុជាប្រជាធិបតេយ្យ ត្រូវរលំរលាយ ?

5.តើការបែងចែកផលកសិកម្មតាមកម្លាំងពលកម្ម (ក្រុមសាមគ្គីបង្កបង្កើនផល) ទទួលបានផលល្អនិងផលអាក្រក់ដូចម្ដេច ?

## ចម្លើយបញ្ចប់ជំពូកទី២

I. គូសសញ្ញា✓ក្នុងប្រអប់ចម្លើយត្រឹមត្រូវ៖

1. បារាំងចូលគ្រប់គ្រងប្រទេសកម្ពុជាដំបូងក្នុងរជ្ជកាលព្រះរាជាខ្មែរនាម ៖

☑ខ. នរោត្តម

2. សង្គមរាស្ត្រនិយមបានចាប់ផ្ដើមឡើងនៅឆ្នាំ ៖

☑ឃ. 1955

3. អ្នកដឹកនាំរបបកម្ពុជាប្រជាធិបតេយ្យ(មេធំជាងគេ) គឺ ៖

☑ក. ប៉ុលពត

II. **បំពេញល្បះខាងក្រោមឱ្យបានត្រឹមត្រូវ**

1. កិច្ចចរចាសន្តិភាពនាទីក្រុងផែអង់តាជីន័រថ្ងៃទី**2**ខែ**ធ្នូ**ឆ្នាំ**1987**។

2. រដ្ឋប្រហារថ្ងៃទី18ខែមីនា ឆ្នាំ1970 ធ្វើឡើងដោយសេនា**ប្រមុខលន់ ណុល និង ស៊ីសុវត្ថិ សិរីមតៈ** ។

3. ពួកខ្មែរក្រហមបានចូលកាន់កាប់ប្រទេសកម្ពុជានៅទី**17 ខែមេសា ឆ្នាំ1975**។

III. គូសភ្ជាប់ឈ្មោះអ្នកដឹកនាំទៅឈ្មោះប្រទេស

| ឈ្មោះអ្នកដឹកនាំ | ឈ្មោះរបប | ចម្លើយ |
|---|---|---|
| 1.ប៉ុលពត<br>2.នរោត្តមសីហនុ<br>3.លន់ណល់<br>4.ហ៊ុនសែន<br>5.ហេងសំរិន | ក.សាធារណរដ្ឋប្រជាមានិតកម្ពុជា<br>ខ. សង្គមរាស្ត្រនិយម<br>គ. កម្ពុជាប្រជាធិបតេយ្យ<br>ឃ. សាធារណរដ្ឋខ្មែរ<br>ង. ព្រះរាជាណាចក្រកម្ពុជា | 1.→គ<br>2.→ខ<br>3.→ឃ<br>4.→ង<br>5.→ក |

IV. <u>ចម្លើយ</u>

1. វត្តមានបារាំងនៅលើទឹកដីខ្មែរផ្តល់ផលវិជ្ជមាននិងអវិជ្ជមានដូចជា៖

❖ **ផលវិជ្ជមាន**

➢ ជួយសិក្សាស្រាវជ្រាវអំពីអំពីវប្បធម៌ខ្មែរនិងជួសជុលប្រាសាទបុរាណខ្មែរ

➢ ជួយទាមទាយកខេត្តមួយចំនួនពីសៀមមកឱ្យខ្មែរវិញដូចជាបាតដំបង និងមហានគរតាមរយៈសន្ធិសញ្ញាបារាំង-សៀមថ្ងៃទី 23 ខែ មីនា ឆ្នាំ1907

- នៅឆ្នាំ 1904 ក្រោមការគាប់សង្កត់របស់បារាំងសៀមបានប្រគល់ខេត្តម្លូព្រៃ ទន្លេពៅ និង ខេត្តកោះកុងមកឱ្យខ្មែរវិញ
- ជួយលើកស្ទួយវិស័យវប្បធម៌ខ្មែរ ជួយពង្រឹងវិស័យអប់រំនៅ ។ នៅឆ្នាំ 1915 គណកម្មការរៀបចំវចនានុក្រមខ្មែរត្រូវបានបង្កើតឡើងដើម្បីធ្វើឱ្យភាសាជាតិមានលក្ខណៈ ប្រាកដនិយម
- វិស័យសសេដ្ឋកិច្ចមាន កសិកម្ម-ឧស្សាហកម្ម (កៅស៊ូ ក្រចៅ ថ្នាំជក់...។
- ជួយលើកស្ទួយជីវភាពកម្មករ និងបង្កើតមន្ទីរពេទ្យដើម្បីព្យា បាលជំងឺកម្មករ
- កសាងគមនាគមស្ពាន ថ្នល់ ផ្លូវរថភ្លើង។

❖ **ផលអវិជ្ជមាន**

- ធ្វើឱ្យសង្គមខ្មែរកាន់តែក្រីក្រឡើង
- ធ្វើឱ្យប្រជាពលរដ្ឋខ្មែរស្លាប់នៅក្នុងសង្គ្រាមលោកលើកទី 1 និងទី2
- ធ្វើឱ្យខ្មែរបាត់បង់វត្ថុកេតនភណ្ឌ
- បាត់បង់ទឹកដីកម្ពុជាក្រោមនិងតំបន់ដាឡាត់ដោយកាត់ឱ្យយួន ។
- ខេត្តត្រាចត្រូវធ្លាក់ក្នុងកណ្តាប់ដៃសៀម។

2.រៀបរាប់អំពីសមិទ្ធផលសង្គមរាស្ត្រនិយមមានដូចជា៖

❖ វិស័យកសិកម្ម៖

- ផលស្រូវនៅឆ្នាំ 1968 ទទួលបាន3 25 000 តោន ។
- ផលកប្បាសនៅឆ្នាំ1964 ទទួលបាន 5 000 តោនក្នុងនោះ 200 តោនបម្រើរោងចក្រតម្បាញក្នុងស្រុក ហើយ 3 000 តោនទៀតនាំចេញទៅក្រៅប្រទេស
- ផលចិញ្ចឹមសត្វ មានសត្វស្លាប គោ ជ្រូក
- បង្កើតក្រុមបសុពេទ្យ ដើម្បីព្យាបាលជំងឺសត្វ។
- រាជរដ្ឋាភិបាលបង្កើត វុត្តទិវានៅគ្រប់ខេត្ត។
- វិស័យនេសាទមានការរីកចម្រើនគួរឱ្យកត់សម្គាល់ និងអាចបម្រើជីវភាពប្រជាពលរដ្ឋកម្ពុជាក្នុងប្រទេស និងនាំចេញទៅលក់នៅបរទេសទៀត ។

❖ វិស័យគមនាគមន៍

- ឆ្នាំ1954ពង្រីកកំពង់ផែភ្នំពេញនិងកសាងកំពង់ផែ ទឹកប្រៃនៅក្រុងព្រះសីហនុ
- នៅឆ្នាំ1956 កសាងផ្លូវជាតិលេខ 4 ពីភ្នំពេញទៅ ក្រុងព្រះសីហនុប្រវែង 226 Km
- ពង្រីកអាកាសយានដ្ឋានអន្តរជាតិពោធិ៍ចិនតុងនិង កសាងអាកាសយានដ្ឋានអន្តរជាតិខេត្តសៀមរាប

➢ ឆ្នាំ 1960 កសាងផ្លូវរថភ្លើងភ្នំ-ក្រុងព្រះសីហនុប្រវែង 270Km

➢ កសាងស្ពានជ្រោយចង្វា(មិត្តភាពកម្ពុជា-ជប៉ុន) ឆ្លងទន្លេសាប

❖ **វិស័យពាណិជ្ជកម្ម**

➢ ក្រុមហ៊ុនពាណិជ្ជកម្មធំៗរបស់បារាំង និងសាខាក្រុមហ៊ុនរបស់សហរដ្ឋអាមេរិចបានដាក់វិនិយោគទុននៅកម្ពុជា។

➢ ការប្រើប្រាស់ឥណទានខាងពាណិជ្ជកម្មក្រៅ ប្រទេស កម្ពុជាបានប្រគួតប្រជែងជាមួយ បារាំង អាមេរិច អង់គ្លេស និងជប៉ុន

➢ រដ្ឋាភិបាលបានបង្កើតក្រុមហ៊ុនពាណិជ្ជកម្មថ្មីឈ្មោះ "ក្រុមហ៊ុនអាហារណៃនីហារណៃ" (សូណិចស៊ីម)

➢ ឆ្នាំ1964 រាជរដ្ឋាភិបាលបានបង្កើតក្រុមហ៊ុនពាណិជ្ជកម្មរដ្ឋនិងឯកជនពីរគឺក្រុមហ៊ុនខ្មែរនៃការ ទិញផលិតផលកសិកម្ម(សូប៉ាប៉ា) និងក្រុមហ៊ុនជាតិនៃការចែករំលែកទំនិញនាំចូល(សូណាព្រីម)

❖ **ឧស្សាហកម្ម៖**

រាជរដ្ឋាភិបាលបានកសាងរោងចក្រជាច្រើនដូចជា៖

➢ រោងចក្រវាយនភ័ណ្ឌ(កំពង់ចាម)

- ' រោងចក្រក្តាបន្ទះដីឥដ្ឋ (កណ្តាល)
- រោងចក្រកែវនៅចំកាដូង(កណ្តាល)
- រោងចក្រក្រដាសឆ្លូង(ក្រចេះ)
- រោងចក្រស៊ីម៉ង់ចក្រីទីង(កំពត)
- រោងចក្រក្រចៅដូនទាវ(បាត់ដំបង)
- រោងចក្រស្ករសកំពង់ត្រាំ(កំពង់ស្ពឺ)
- រោងចក្រស្រាបៀរនិងដំឡើងត្រាក់ទ័រ(ក្រ.ព្រះសីហនុ)

❖ វិស័យវប្បធម៌ ៖

- រាជរដ្ឋាភិបាល បានយកចិត្តទុកដាក់លើវិស័យសិក្សាធិការជាតិដោយបណ្តោះបណ្តាលគ្រូបង្រៀន កសាងសាលារៀនចាប់ពីបឋមសិក្សាដល់សាកលវិទ្យាល័យ
- បានបញ្ជូននិស្សិតខ្មែរឱ្យទៅសិក្សានៅបរទេសជាពិសេសប្រទេសបារាំង។
- លើកស្ទួយវិស័យកីឡា
- យកចិត្តទុកដាក់លើវិស័យសាសនាដោយបាន បង្កើតពុទ្ធិកបឋមសិក្សាដល់ពុទ្ធិកមហាវិទ្យាល័យ។

❖ វិស័យសង្គមកិច្ច

➢ មានការកសាងមន្ទីពេទ្យគ្រប់ខេត្តក្រុង

➢ ការអភិវឌ្ឍជនបទដូចជាការរក្សាអនាម័យតាមលំនៅឋាន ជីកអណ្តូងទឹក សង់ផ្ទះ ជីកស្រះ ឱ្យប្រជារាស្ត្រ។

➢ បង្កើតមជ្ឈមណ្ឌលអប់រំស្ត្រីពេស្យានៅទួលគកនិង ផ្តល់សិទ្ធិឱ្យស្ត្រីឈរឈ្មោះបោះឆ្នោតនិងមានសិទ្ធិ បោះឆ្នោត។

3.ផលវិបាកនៃសង្គ្រាមស៊ីវិលក្នុងរបបលន់ណល់បានធ្វើឱ្យសង្គមខ្មែរជួបប្រទះនូវ៖

➢ អំពើពុករលួយ

➢ ស្លាប់ របួស ពិកា ស្រីមេម៉ាយ កុមារកំព្រា

➢ ភាពក្រីក្រ

➢ ខូចខាតទ្រព្យសម្បត្តិ ផ្ទះសំបែង រោងចក្រ ផ្លូវថ្នល់សាលារៀន មន្ទីពេទ្យ។

4.បានជារបបកម្ពុជាប្រជាធិបតេយ្យដួលរលំ ដោយសារ៖

- ប្រជាជនស្អប់របបប៉ុល ពត
- វិសុទ្ធកម្ម( ការចំរាញយកមនុស្សបដិវត្តន៍បរិសុទ្ធ )
- ការធ្វើសង្គ្រាមជាមួយប្រទេសវៀតណាម។

5.ការបែងចែកផលកសិកម្មតាមកម្លាំងពលកម្ម (ក្រុមសាមគ្គីបង្កបង្កើនផល)ទទួលបានផលល្អនិងផលអាក្រក់ដូចជា៖

❖ទទួលបានផលល្អ

- ជួយសម្រាលអ្នកដែលគ្មានកម្លាំងពលកម្មដូចជា ស្ត្រីមេម៉ាយ ក្មេងកំព្រា និងមនុស្សចាស់ជរា
- អាចឱ្យប្រជាជនរស់ផុតពីសេចក្ដីស្លាប់ដែលទើបតែចេញពីរបបប៉ុលពត។

❖ផលអាក្រក់

- អ្នកដែលមានកម្មសិទ្ធិឯកជនត្រូវខាត់បង់នូវអ្វីដែលជារបស់ខ្លួនដើម្បីចែកទៅដល់មនុស្សផងគ្នា

# ជំពូកទី៣ ប្រវត្តិសាស្ត្រតំបន់ក្នុងសង្គ្រាមត្រជាក់

## មេរៀនទី1 បម្រែបម្រួលអាស៊ីអាគ្នេយ៍ក្រោយសង្គ្រាមលោកលើកទី2

## សំណួរ

1. តើចលនាតស៊ូមានប៉ុន្មានបែប ? អ្វីខ្លះ ?
2. តើអ្នកណា ជាកម្លាំងស្នូលនៅក្នុងការដឹកនាំចលនាតស៊ូដើម្បីឯករាជ្យជាតិទាំងនេះ ?
3. តើភាពរីកចម្រើនអ្វីខ្លះ ដែលគួរឱ្យកត់សម្គាល់នៅក្នុងបណ្តាប្រទេសអាស៊ីអាគ្នេយ៍ក្នុងដំណាក់កាលក្រោយការទទួលឯករាជ្យជាតិ

## ចម្លើយ

1. ចលនាតស៊ូមាន2បែបគឺ ៖

➢ ការតស៊ូដើម្បីឯករាជ្យជាតិ ប្រឆាំងនឹងរបបអាណានិគមនិយមអង់គ្លេសបារាំង

➢ ការតស៊ូប្រឆាំងនឹងពួកមូលធននិងសក្តិភូមិ។

2. អ្នកដែលជាកម្លាំងស្នូលនៅក្នុងការដឹកនាំចលនាតស៊ូដើម្បីឯករាជ្យជាតិទាំងនេះ គឺបញ្ញាវន្ត។

៣.ភាពរឹករវែដែលគួរឱ្យកត់សម្គាល់នៅក្នុងបណ្ដាប្រទេសអាស៊ីអាគ្នេយ៍ក្នុងដំណាក់កាលក្រោយការទទួលឯករាជ្យជាតិ មានដូចជា៖

- សង្គ្រាមនៅតំបន់ឥណ្ឌូចិន(ខ្មែរ ឡាវ វៀតណាម)
- ប្រទេសមីយ៉ានម៉ាដឹកនាំនយោបាយមិនចូលបក្សសម្ព័ន្ធក្រោមរដ្ឋអំណាចយោធា
- បញ្ហាទាក់ទងនឹង ជនជាតិ(ការរមលោភសិទ្ធិជនជាតិភាគតិច)
- បញ្ហាទាក់ទង់នឹងសាសនា(ការបះបោពួកអ៊ីស្លាម នៅប្រទេសហ្វីលីពីន...)
- សង្គ្រាមវៀតណាមអាមេរិច
- ការផ្ដួលរលំស៊ូកាណូពីអំណាចនៅឆ្នាំ 1967(ឥណ្ឌូណេស៊ី)។

## មេរៀនទី2 ប្រទេសវៀតណាម (VEITNAM)

### សំណួរ

1. ហេតុដូចម្ដេចបានជាកងទ័ពវៀតណាមខាងជើង ទទួលបានជ័យជំនះលើកងទ័ពវៀតណាមខាងត្បូង និងសហរដ្ឋអាមេរិច
2. ហេតុអ្វីបានជាក្រោយសង្គ្រាមឆ្នាំ1975 សេដ្ឋកិច្ចវៀតណាមត្រូវហ៊ុមព័ទ្ធដោយលោកខាងលិច ?
3. តើ "ដូយម៉ុយ" មានគោលការណ៍ជាមូលដ្ឋានយ៉ាងណាខ្លះដើម្បីអភិវឌ្ឍសេដ្ឋកិច្ចវៀតណាម ?

### ចម្លើយ

1. បានជាកងទ័ពវៀតណាមខាងជើង ទទួលបានជ័យជំនះលើកងទ័ពវៀតណាមខាងត្បូងនិងសហរដ្ឋអាមេរិច ពីព្រោះដោយសារ

- ពួកគេមានកម្លាំងច្រើននិងប្រកបដោយបទពិសោធខ្ពស់ក្នុងការធ្វើសឹកសង្គ្រាម
- ប្រទេសផ្សេងៗមិនបានគាំទ្រសហរដ្ឋអាមេរិច ក្នុងការធ្វើសង្គ្រាម
- មានបាតុកម្មនៅសហរដ្ឋអាមេរិច កុំឱ្យធ្វើសង្គ្រាមនៅវៀត ណាម

2. បានជាក្រោយសង្គ្រាមឆ្នាំ1975 សេដ្ឋកិច្ចវៀតណាមត្រូវហ៊ុម ព័ទ្ធដោយលោកខាងលិច ពីព្រោះ

➢ វៀតណាមរស់នៅដោយកាត់ ផ្តាច់ពីទំនាក់ទំនងពីពិភពខាងក្រៅ

➢ វៀតណាមមានទំនាក់ទំនង់ជាមួយសហភាពសូវៀតដែលជាប្រទេសកុំម៉ុយនីស។

3. គោលការណ៍ជាមូលដ្ឋានរបស់"ដូយម៉ុយ" ដើម្បីអភិវឌ្ឍសេដ្ឋកិច្ចវៀតណាម គឺ ដើម្បីថែរក្សាស្ថេរភាពនយោបាយនៅក្នុងសង្គម កសាងទំនាក់ទំនងល្អលើនយោបាយការបរទេសក្នុងឆាកអន្តរជាតិនិងតំបន់ ដើម្បីរុញប្រទេសចេញឱ្យផុតពីស្ថានភាពហ៊ុមព័ទ្ធនិងការដាក់ទណ្ឌកម្មសេដ្ឋកិច្ច និងជំរុញប្រទេសឱ្យចូលរួមទៅក្នុងសមាហរណកម្មនយោបាយ និងសេដ្ឋកិច្ចលើសកលលោក។

# មេរៀនទី3 ប្រទេសថៃ (Thailand)

## សំណួរ

1. តើស្តេច មង្គុត និងជូឡាឡុងកន បានដឹកនាំនយោបាយកំណែទម្រង់សង្គមសៀមយ៉ាងដូចម្តេច ?
2. តើមូលហេតុអ្វីបានជាផ្ទុះរឿងបដិវត្តិន៍ឆ្នាំ1932?
3. តើអំណាចយោធាមានតួនាទីយ៉ាងណាក្នុងប្រទេសថៃ ?
4. តើស្តេច "ភូមិពលអាឌុលយ៉ាតេជ" បានធ្វើសកម្មភាពអ្វីខ្លះដើម្បីពង្រឹងស្ថាប័នព្រះមហាក្សត្រឡើងវិញ ?
5. តើព្រះមហាក្សត្រមានតួនាទីអ្វីខ្លះ ក្នុងប្រព័ន្ធដឹកនាំរបបរាជានិយមអាស្រ័យរដ្ឋធម្មនុញ្ញថៃ ?

## ចម្លើយ

1. ស្តេច មង្គុត និងជូឡាឡុងកន បានដឹកនាំនយោបាយកំណែទម្រង់សង្គមសៀមគឺៈ

➢ ព្រះអង្គក្លាហានក្នុងការទទួលយកសមិទ្ធផលនៃរចនាសម្ព័ន្ធដឹកនាំបែបលោកខាងលិច តាមការអប់រំបច្ចេកវិទ្យានិងការអនុវត្តផ្ទាល់នៅក្នុងសង្គមសៀម។

➢ ធ្វើទំនើបកម្មសង្គមសៀម ជាពិសេសលើរចនាសម្ព័ន្ធគ្រប់គ្រងរដ្ឋបាល និង ហិរញ្ញវត្ថុ។

➢ប្រព័ន្ធដឹកនាំរដ្ឋបាលដែនដី ត្រូវបានធ្វើកំណែទម្រង់ជាច្រើនដំណាក់កាលក្នុងទិសដៅបញ្ចប់ប្រព័ន្ធដឹកនាំស្វ័យភាព

➢លុប បំបាត់ស្ថានភាពខុសគ្នាតាមតំបន់ លុបប្រព័ន្ធ "ចិញ្ចឹម" និង អំណាចចំណុះ នៅតាមជនបទដោយដាក់ជំនួសវិញនូវអំណាចកណ្តាល

➢មន្ត្រីអាជ្ញាធរមូលដ្ឋានត្រូវទទួលការតែងតាំង និងទទួលប្រាក់បៀវត្សពីអំណាចកណ្តាល។

➢បង្កើតប្រព័ន្ធអប់រំសាធារណៈ លប់បំបាត់កម្មសិទ្ធសក្តិភូមិ។

➢បញ្ជូនយុវជនឱ្យទៅសិក្សានៅក្រៅប្រទេស(អឺរ៉ុប)

2.បានជាមានផ្ទុះរឿងបដិវត្តិន៍ឆ្នាំ1932 ដោយសារតែនៅឆ្នាំ 1886 ក្រុមយុវជនបញ្ញវន្តសៀមទី១បានត្រលប់មកពីទ្វីបអឺរ៉ុប ពួកគេ បានធ្វើញាត្តិស្នើសុំព្រះមហាក្សត្របង្កើតសភាជាតិ ក្រុមប្រឹក្សារដ្ឋមន្ត្រី អនុម័តច្បាប់ការពាសិទ្ធិមនុស្ស សេរីភាពក្នុងការបញ្ចេញមតិ និងសមភាពប្រជាពលរដ្ឋចំពោះមុខច្បាប់។ព្រះមហាក្សត្រពុំបាន ធ្វើតាមការទាមទារឡើយ។

3.តួនាទីអំណាចឃោជាក្នុងប្រទេសថៃ ៖

➢រៀបចំនយោបាយសេដ្ឋកិច្ចនិងសង្គម

➢ធ្វើផែនការអភិវឌ្ឍ

➢ស្នើសុំព្រះរាជអន្តរាគមន៍ពីស្ថាប័នព្រះមហាក្សត្រដើម្បីជានា

ប្រក្រតីភាពស្ថាប័ននិងសណ្តាប់ធ្នាប់សង្គម។

4. ស្តេច "ភូមិពលអាឌុលយ៉ាតេជ"បានធ្វើសកម្មភាពដើម្បីពង្រឹ ស្ថាប័នព្រះមហាក្សត្រឡើងវិញ ដូចជាព្រះអង្គបានធ្វើដំណើ ទៅគ្រប់ទីកន្លែងទូទាំងប្រទេស និងផ្តល់ឱកាសឱ្យកសិករចូល គាល់ ព្រះអង្គដោយផ្ទាល់ជាមួយនឹងការលាតត្រដាងកង្វល ផ្ទាល់ខ្លួន។ មន្ត្រីរាជការ ក្រុមគ្រូពេទ្យ និងអ្នកឯកទេ កសិកម្មជាដើម បានធ្វើដំណើរអមព្រះរាជទស្សនកិច្ចតាមជ បទក្នុងទិសដៅផ្តល់ការថែទាំ សុខុមាលភាពដល់ប្រជាកសិក អភិវឌ្ឍន៍ប្រព័ន្ធអប់រំនៅតាមមូលដ្ឋាន បង្ហាត់បង្រៀនបច្ចេ វិទ្យាកសិកម្មថ្មី ជម្រើសពូជសត្វ ពាហនៈ ធ្វើផ្លូវនិងប្រព័ ស្រោចស្រព ។

5. តួនាទីព្រះមហាក្សត្រ ក្នុងប្រព័ន្ធដឹកនាំរបបរាជានិយមស្រ័ រដ្ឋធម្មនុញ្ញថៃគឺ៖

➢ សម្របសម្រួល នៅក្នុងព្រះរាជអន្តរាគមន៍ឱ្យមានស្ថិរភា នយោបាយនិងសេដ្ឋកិច្ចក្នុងសង្គមថៃ។

## មេរៀនទី4 បណ្តាប្រទេសនៅតំបន់មជ្ឈិមបូព៌ា

### សំណួរ

1. តើប្រភព នៃទំនាស់នៅក្នុងតំបន់មជ្ឈិមបូព៌ាលេចចេញមកពីបញ្ហាអ្វី ?
2. ហេតុដូចម្តេចបានជាប្រទេសមហាអំណាច ប្រគួតប្រជែងគ្នាដើម្បីគ្រប់គ្រងតំបន់មជ្ឈិមបូព៌ា ?
3. ហេតុដូចម្តេច បានជាបណ្តាប្រទេសអារ៉ាប់ដែលជាប្រទេសសំបូរទៅដោយធនធានស្តុកស្តម្ភ ប្រជាជនច្រើន ប៉ុន្តែមិនអាចយកជ័យជំនះទៅលើប្រទេសអ៊ីស្រាអែលបាន ?

### ចម្លើយ

1. ប្រភពនៃទំនាស់នៅក្នុងតំបន់មជ្ឈិមបូព៌ាលេចចេញមកពីបញ្ហាមួយចំនួនដូចជា៖
- សាសនាចម្រុះ
- ជនជាតិចម្រុះសាសន៍
- ទឹកដី( ព្រំប្រទល់ ...)
- បញ្ហាប្រេង
- ការជ្រៀតជ្រែករបស់ប្រទេសមហាអំណាច។

2. បានជាប្រទេសមហាអំណាចប្រគួតប្រជែងគ្នា ដើម្បីគ្រប់គ្រងតំបន់មជ្ឈិមបូព៌ា ពីព្រោះតំបន់មជ្ឈិមបូព៌ាជាតំបន់ដែលសំបូរទៅដោយធានធានប្រេងកាត ។

3. បានជាបណ្តាប្រទេសអារ៉ាប់ដែលជាប្រទេសសំបូរទៅដោយធនធានស្តុកស្តម្ភ ប្រជាជនច្រើន ប៉ុន្តែមិនអាចយកជ័យជំនះទៅលើប្រទេសអ៊ីស្រាអែលបាន ពីព្រោះ៖

- ប្រទេសទាំងនោះមានជំលោះផ្ទៃក្នុង
- មេដឹកនាំអារ៉ាប់អួតអាងអំណាចហួសហេតុពេក ច្រើនតែអតនោម័តតែរៀងៗខ្លួន
- ប្រទេសអ៊ីស្រាអែលមានកំលាំងយោធាដ៏រឹងមាំ។

## មេរៀនទី5 ប្រទេសអ៊ីស្រាអែល(Israel)

### សំណួរ

1. តើរដ្ឋអ៊ីស្រាអែលថ្មីបានលេចឡើងយ៉ាងដូចម្ដេច ?
2. តើជនជាតិជ្វីបមានមនសិការជាតិយ៉ាងណាខ្លះ ?ចូរពន្យល់ ?
3. ការរស់នៅរបស់ជនជាតិជ្វីបនៅទីកន្លែងផ្សេងៗគ្នា សូម្បីតែភាសាក៏ផ្សេងគ្នាទៅហើយ ចុះកត្តាអ្វីជាឫសគល់ជំរុញឱ្យជនជាតិ នេះអាចរួបរួមគ្នាបង្កើតរដ្ឋជ្វីបដ៏ខ្លាំងបន្លានេះឡើងវិញបាន ?
4. តើបណ្ដាប្រទេសអារ៉ាប់មានចំណុចខ្សោយត្រង់ណា ទើបមិនអាចទទួលជោគជ័យលើអ៊ីស្រាអែលបាមនៅក្នុងសង្គ្រាមប្រាំមួយ ថ្ងៃ ?

### ចម្លើយ

1. រដ្ឋអ៊ីស្រាអែលថ្មីបានលេចឡើងនៅពេលដែលអង់គ្លេសបានដាក់អាណានិគមលើទឹកដីប៉ាលេស្ទីន។ ដោយសារតែមានជនជាតិពីរផ្សេងគ្នារស់នៅលើទឹកដីតែមួយ ទើបគេបានបង្កើតប្រទេសអ៊ីស្រាអែស នេះឡើង នៅក្នុងឆ្នាំ 1947។
2. មនសិការរបស់ជនជាតិជ្វីប៖

ទោះបីជាពួកគេរស់នៅតំបន់ផ្សេងៗ គ្នាក៏ដោយពួកគេនៅតែថែរក្សាសាសនា ប្រពៃណី វប្បធម៌ និង ជំនឿរបស់ជានិច្ច។ ដាក់

ស្តែងនៅពេលប្រទេសរបស់ខ្លួនមានសង្គ្រាមពួកគេ ទាំងប្រុស ទាំងស្រីបានចូលទៅបម្រើ កងទ័ពដើម្បីប្រឆាំងជាមួយសត្រូវឈ្លានពាន។

3.ការរស់នៅរបស់ជនជាតិជ្វីបនៅកន្លែងផ្សេងៗគ្នា សូម្បីតែកាសាក៏ផ្សេងគ្នាទៅហើយ កត្តាជាឫសគល់ជំរុញឱ្យជនជាតិនេះអាចរួបរួមគ្នា បង្កើតរដ្ឋជ្វីបដ៏ខ្លាំងខ្លានេះឡើងវិញបាន គឺ៖

- មេដឹកនាំល្អ
- ទទួលជនជាតិជ្វីប ឱ្យមករស់នៅក្នុងប្រទេសអ៊ីស្រាអែលទាំងអស់
- ស្រលាញ់សន្តិភាព
- មានការគាំទ្រពីប្រទេសមហាអំណាច
- មានមនសិការជាតិដ៏ជ្រាលជ្រៅ
- មានបទពិសោធន៍បាត់បង់ទឹកដីជាទីស្រលាញ់របស់ពួកគេ

3.បណ្តាប្រទេសអារ៉ាប់មានចំណុចខ្សោយត្រង់ណា ទើបមិនអាចទទួលជោគជ័យលើអ៊ីស្រាអែលបាន នៅក្នុងសង្គ្រាមប្រាំមួយថ្ងៃគឺ ៖

- មិនមានការត្រៀមក្នុងការធ្វើសង្គ្រាម
- មិនមានការរួបរួមគ្នា
- អតនោម័តរបស់អ្នកដឹកនាំតែរៀងៗខ្លួន។

# សំណួរបញ្ចប់ជំពូកទី3

I. ចូរគូសសញ្ញា✓ក្នុងប្រអប់ចម្លើយត្រឹមត្រូវ

1. តើនិមិត្តសញ្ញាអាស៊ានមានរាងជាអ្វី ?

☐ក. រាងស្រូវ ☐ខ. កណ្ដាបស្រូវ

☐គ. ត្បាល់បុក ☐ឃ. ជើងពាន

2. តើប្រទេសវៀតណាមស្ថិតក្រោមការត្រួតត្រារបស់បារាំងនៅឆ្នាំណា ?

☐ក. 1859 ☐ខ. 1863

☐គ. 1884 ☐ឃ. 1885

3. តើនៅមជ្ឈិមបូព៌ាមានប្រទេសប៉ុន្មាន ?

☐ក. 8ប្រទេស ☐ខ. 9ប្រទេស

☐គ. 11ប្រទេស ☐ឃ. 12ប្រទេស

II. ចូរបំពេញឃ្លាខាងក្រោមឱ្យបានត្រឹមត្រូវ

1. ប្រទេសអ៊ីស្រាអែលជាប្រទេសចំនាស់មួយដែលមានជនជាតិដើមគឺពួក......................។

2. ប្រទេសវៀតណាមទទួលឯករាជ្យពីអាណានិគមបារាំងនៅឆ្នាំ................។

3. ក្រោយព្រឹត្តិការណ៍បដិវត្តិន៍ឆ្នា1932រហូតដលសព្វថ្ងៃអំណាចព្រះមហាក្សត្រថៃចុះ.........................។

III. ចូរគូសភ្ជាប់ឈ្មោះប្រធានាធិបតីទៅឈ្មោះប្រទេស

| ឈ្មោះអ្នកដឹកនាំ | ឈ្មោះប្រទេស | ចម្លើយ |
|---|---|---|
| 1. ហូជីមិញ | ក. អ៊ីស្រាអែល | 1. → |
| 2. ជូឡាឡុងកន | ខ. វៀតណាម | 2. → |
| 3. រ៉ាយស្មាន់ | គ. ថៃ | 3. → |

IV. សំណួរត្រិះរិះ

1. តើចលនាតស៊ូដើម្បីឯករាជ្យមានប៉ុន្មានបែបគឺអ្វីខ្លះ ?

2. តើដូយម៉ុយជាអ្វី ? តើការអនុវត្តរបស់ដូយម៉ុយមានសិទ្ធិភាព ឬទេ ?ព្រោះអ្វី?

3. តើតួនាទីស្តេចថៃក្នុងរដ្ឋធម្មនុញ្ញថៃមានអ្វីខ្លះ ?

4. តើប្រភពនៃទំនាស់នៅក្នុងតំបន់មជ្ឈិមបូព៌ាចេញពីបញ្ហាអ្វី ?

## ចម្លើយបញ្ចប់ជំពូកទី3

I. គូសសញ្ញា✓ក្នុងប្រអប់ចម្លើយត្រឹមត្រូវ

1. និមិត្តសញ្ញាអាស៊ានមានរាងជា

☑ឃ. ដើងពាន

2. ប្រទេសវៀតណាមស្ថិតក្រោមការត្រួតត្រារបស់បារាំង នៅឆ្នាំ

☑ឃ. 1885

3. នៅមជ្ឈិមបូព៌ាមានប្រទេសចំនួន៖

☑ឃ. 12ប្រទេស

II. បំពេញល្បះខាងក្រោមឱ្យបានត្រឹមត្រូវ

4.ប្រទេសអ៊ីស្រាអែលជាប្រទេសចំនាស់មួយដែលមានជនជាតិដើមគឺពួក ជ្វីប ។

5.ប្រទេសវៀតណាមទទួលឯករាជ្យពីអាណានិគមបារាំងនៅឆ្នាំ 1945 ។

6.ក្រោយព្រឹត្តិការណ៍បដិវត្តិន៍ឆ្នាំ 1932រហូតដលសព្វថ្ងៃអំណាចព្រះមហាក្សត្រថៃចុះ ថយឥទ្ធិពល ។

III. គូសភ្ជាប់ឈ្មោះប្រធានាធិបតីទៅឈ្មោះប្រទេស

| ឈ្មោះអ្នកដឹកនាំ | ឈ្មោះប្រទេស | ចម្លើយ |
|---|---|---|
| 1. ហូជីមិញ<br>2.ជូឡាឡុងកន<br>3.វ៉ាយស្មាន់ | ក. អ៊ីស្រាអែល<br>ខ. វៀតណាម<br>គ. ថៃ | 1. →ខ<br>2. →គ<br>3. →ក |

IV.<u>ចម្លើយ</u>

1. ចលនាតស៊ូមាន2បែប គឺ

➢ការតស៊ូប្រឆាំងនឹងពួកមូលធននិងសក្តិភូមិ

➢ការតស៊ូដើម្បីឯករាជ្យជាតិ ប្រឆាំងនឹងរបបអាណានិគមនិយមអង់គ្លេស បារាំង។

2.ដូយម៉ឺយជាគឺជាកំណត់កម្មវិធីនយោបាយថ្មី គឺកំណែទម្រង់ រ៉ាឌីកាល់ទៅលើរចនាសម្ព័ន្ធសេដ្ឋកិច្ចទាំងស្រុងនិងបើកទ្វារផ្តល់

លទ្ធភាពដល់សហគ្រិនធ្វើសកម្មភាពនៅក្នុងប្រព័ន្ធសេដ្ឋកិច្ចទីផ្សារសេរី។ បើតាមន័យនយោបាយ"ដូយម៉ីយ"គឺជាការ ចាប់បដិសន្ធិនៃការដឹកនាំថ្មី និងក្មេងខ្ចីមួយសមស្របតាម ស្ថានការណ៍រដ្ឋបាលក្នុងស្រុក។ ការកែទម្រង់ក្នុងជួរបក្ស និង ជុំវិញការគ្រប់គ្រង ដេញដោលរដ្ឋាភិបាល និងចញ្ចេញយោ បល់ដោយសេរី។

❖ ការអនុវត្តរបស់ដូយម៉ីយមានប្រសិទ្ធិភាពព្រោះក្រោយពេលអនុវត្តដូយម៉ីយប្រ ទេសវៀតណាមមានកំណើនសេដ្ឋកិច្ចយ៉ាងខ្លាំង ដោយសារកោរីកចម្រើនវិស័យឧស្សាកម្ម វិស័យកសិកម្ម លើសពីនេះទៅទៀតអ្នកវិនិយោគទុនបរទេសកាន់ច្រើនមកដាក់វិនិយោគនៅក្នុងប្រទេសវៀត ។

3. តួនាទីស្តេចថៃក្នុងរដ្ឋធម្មនុញ្ញថៃគឺ៖

➢ សម្របសម្រួលនៅក្នុងព្រះរាជអន្តរាគមន៍ឱ្យមានស្ថិរភាពនយោបាយនិងសេដ្ឋកិច្ចក្នុងសង្គមថៃ។

4. ប្រភពនៃទំនាស់នៅក្នុងតំបន់មជ្ឈិមបូព៌ាចេញពីបញ្ហា៖

➢ ទឹកដីដ៏សាំញ៉ាំ

➢ ចម្រុះដោយជនជាតិ ផ្សេងៗ

➢ ចម្រុះដោយសាសនាផ្សេងអ៊ីស្លាមនិកាយផ្សេងៗ គ្រឹស្តសាសនា និកាយផ្សេងៗៗ

- កំណាប់ប្រេងដ៏ច្រើនមហាសាល។
- រងឥទ្ធិពលពីប្រទេសមហាអំណាចដើម្បីផល ប្រយោជន៍របស់ពួកគេ។

# ចប់